# ជំពូក ១៤

# ប្រទេសខ្មែរក្រោមអាណាព្យាបាលបារាំង

## (ស.វ.ទី ១៩ និងទី ២០)

## ក. ហេតុអ្វីបានជាមានអាណាព្យាបាលបារាំង ?

### ១. ព្រះបាទនរោត្តម (១៨៥៩-១៩០៤)




(រូបស្រង់ពីសៀវភៅសិក្សាសង្គម ថ្នាក់ទី១១ ទំព័រ១៩៩ បោះពុម្ពឆ្នាំ២០០០)

នៅពេលដែលព្រះបាទហារិរក្សរាមាឥស្សរាធិបតី សោយទិវង្គតទៅ ពួកមន្ត្រី និងព្រាហ្មណ៍បុរោហិត បានលើកព្រះរាជបុត្រច្បងនាម **អង្គច្រឡឹង** ឬ**អង្គវតី** អោយឡើងគ្រងរាជ្យស្នងព្រះបិតានៅរាជធានី**ឧដុង្គ** ។

កិច្ចការដែលព្រះអង្គត្រូវបំពេញជាដំបូង គឺការថ្វាយដំណឹងទៅព្រះចៅសៀម ពីការជ្រើសរើសអោយព្រះអង្គឡើងគ្រងរាជ្យ ។ព្រះចៅសៀមបានបញ្ជូនមន្ត្រីម្នាក់មករាជធានី **ឧដុង្គ**ដើម្បីបញ្ជាក់ពីការយល់ព្រមរបស់ព្រះអង្គ និងដើម្បីចូលរួមក្នុងព្រះរាជពិធីបុណ្យសពព្រះ**អង្គដួង** ផង ។ នៅពេលជាមួយគ្នានោះ ព្រះ **អង្គស៊ីវត្ថា** ព្រះរាជបុត្រទី៣របស់ព្រះ **អង្គដួង** ក៏បានយាងត្រឡប់ចូលស្រុកវិញដែរ ។

## ២. ការតស៊ូរបស់ខ្មែរនៅកម្ពុជាក្រោម

គួរកត់សំគាល់ថា នៅខាងដើមរជ្ជកាលនៃព្រះបាទ **នរោត្តម** ខ្មែរនៅកម្ពុជាក្រោម បានបន្តការតស៊ូរបស់ខ្លួនប្រឆាំងនឹងអំពើឈ្លានពានរបស់យួនទៀត ។

នៅគ.ស. ១៨៥៩ ពួកយួនបានរៀបចំគំរោងការថ្មីហើយបានទាក់ទាញពួកចាមដែលភៀសទៅនៅ **មាត់ជ្រូក** អោយចូលខាងខ្លួន ។ ដូច្នេះខ្មែរនៅកម្ពុជាក្រោមត្រូវតស៊ូជាថ្មីទៀត : លោកសេនា **សួស** និងបក្សពួករបស់លោកបានក្រោកឡើងប្រយុទ្ធនឹងយួននៅ **មហានប់** និង **ចុងបល្លង្គ** ក្នុងខេត្ត **ឃ្លាំង** ។ ក្នុងរយៈពេល៣ឆ្នាំនៃការតស៊ូ ខាងខ្មែរតែងបានទទួលជោគជ័យជានិច្ច ប៉ុន្តែជាអកុសល ! នៅទីបំផុតលោកសេនា **សួស** ត្រូវទទួលមរណភាពដោយថ្នាំបំពុលរបស់ពួកចាមដែលចុះចូលខាងយួន ។

នៅឆ្នាំបន្ទាប់មកទៀត គឺនៅគ.ស.១៨៦០ មានបងប្អូនពីរនាក់ ឈ្មោះសេនា **ធា** និងសេនា **មន** បានក្រោកឡើងប្រឆាំងនឹងយួនទៀតនៅ **លំពួយា** ក្នុងខេត្ត **ឃ្លាំង**ដដែល ។ ដំបូងទ័ពខ្មែរទន់ដៃជាងត្រូវដកថយចូលទៅខេត្ត **ពលលាវ** នៅត្រង់តំបន់ **ត្រាខា** ។ ក្រោយមកក៏មានជោគជ័យវិញ ហើយដេញតាមកំចាត់ទ័ពយួនរហូតដល់ **ពាម ពលលាវ** ។ ប៉ុន្តែនៅទីនោះយួនមានទ័ពជំនួយមកជួយ ហើយលោកសេនា **ធា** ក៏ត្រូវទទួលមរណភាពទៀត ដោយត្រូវគ្រាប់កាំភ្លើងរបស់ជ្វាបាញ់ ។ សពរបស់លោកត្រូវបានដឹកនាំយកទៅកប់នៅក្បែរវត្ត **ខ្វែងបរែល** ក្នុងភូមិ **ហ៊ុង ហូយ** (Hung-hôi) សព្វថ្ងៃ ។

## ៣. ការបះបោររបស់ព្រះអង្គស៊ីវត្ថា (១៨៦១-១៨៦២)

លោក Moura បានសរសេរថា ទោះបីព្រះបាទ**នរោត្តម** ទ្រង់បានទទួលរាក់ទាក់ និងជួយទំនុកបំរុងយ៉ាងណាក៏ដោយក៏ព្រះអង្គមិនអាចបំបាត់អោយអស់នូវការច្រណែនរបស់ព្រះអនុជរបស់ព្រះអង្គដែរ ។ ដោយពុំមានហេតុផលអ្វីអោយសមរម្យផង ព្រះ**អង្គស៊ីវត្ថា** បានគិតថា ព្រះរៀមព្រះអង្គទាំងពីរគឺ **នរោត្តម** និង **ស៊ីសុវត្ថិ** មិនត្រូវមានសិទ្ធិឡើងសោយរាជសម្បត្តិដែលត្រូវតែបានទៅព្រះអង្គជាដាច់ខាត ។ ម្ល៉ោះហើយ ព្រះអង្គក៏បញ្ចេញអាកប្បកិរិយារឹងរូស មិនគោរព មិនស្តាប់បង្គាប់ព្រះរៀម មិនឡើងគាល់ព្រះរៀម ហើយនៅទីបំផុតបានគេចបាត់ពីរាជធានីតែម្តង (គ.ស.១៨៦១) ។

ចម្បាំងគ្នាឯងក្នុងស្រុកបានកើតឡើងជាថ្មីទៀត ។ តែមិនបានយូរប៉ុន្មានព្រះអង្គ **ស៊ីវត្ថា** បានភៀសព្រះអង្គទៅប្រទេសសៀមជាមួយព្រះអនុជនាម **សិរីវង្ស** ។ ទោះបីព្រះអង្គភៀសទៅហើយក៏ចម្បាំងនៅមិនទាន់ចប់ ព្រោះបក្សពួករបស់ព្រះអង្គគឺស្នង **សួរ** និង **កំហែងយុទ្ធា** (ឯកសារខ្លះថាឈ្មោះ **មនោកែវ**) បានបន្តសកម្មភាពទៅទៀត ។ មេដឹកនាំទាំងពីរនេះបានទៅបំបះបំបោររាស្ត្រនៅតំបន់បាភ្នំ ស្វាយរៀង ឯពួកចៅហ្វាយខេត្តសឹងចុះចូលទាំងអស់ ។

ពួកបះបោរលើកទៅវាយយកបានក្រុង **ភ្នំពេញ** ។ ពេលនោះ ដោយពុំមានទ័ពគ្រប់គ្រាន់ព្រះបាទ **នរោត្តម** ទ្រង់ភៀសព្រះអង្គទៅគង់នៅ **បាត់ដំបង** សិន ។ រាជធានី**ឧដុង្គ** ត្រូវយកបានទៀត ប៉ុន្តែពួកចាមជ្វាដែលបានរត់ទៅមាត់ជ្រូកពីមុនបានសុំសម្តេច**នរោត្តម** ធ្វើការរាជការថ្វាយ ហើយបានប្រយុទ្ធនឹងពួកបះបោរវិញ ។

ពេលនោះ ព្រះចៅសៀមទ្រង់អោយយាងសម្តេច**នរោត្តម** ទៅ **បាងកក** ។

ការប្រយុទ្ធគ្នាបានបន្តទៅទៀតនៅត្រើយខាងកើត ។ ជោគជ័យត្រូវបានទៅខាងទ័ពព្រះ**នរោត្តម** ដែលបានយាងត្រឡប់ចូលប្រទេសវិញនៅខែមីនា ១៨៦២ ដោយមានការគាំទ្រពីព្រះចៅសៀម ។ នៅខែតុលានៃឆ្នាំដដែល **យុទ្ធា** (មនោកែវ) ត្រូវគេសម្លាប់បាន ឯស្នង**ស្វរ** ត្រូវរបួសបានភៀសទៅស្រុកក្រោម ទៅពឹងមេទ័ពបារាំងនៅរោងដំរី បារាំងក៏ចាប់យកទៅដាក់ក្នុងកោះ ។ ដូច្នេះ វិបត្តិក្នុងរាជវង្សក៏ត្រូវដោះស្រាយបានចាប់ពីពេលនោះមក ។

## ៤. សន្ធិសញ្ញា ថ្ងៃទី ១១ សីហា ១៨៦៣

សន្ធិសញ្ញានេះបានបើកអោយបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរជាលើកដំបូង ។ តំណាងអំណាចរបស់បារាំងនេះបានចោទជាចំណោទមួយចំពោះអ្នកប្រវត្តិសាស្ត្រដែលតែងតែចោទសួរថា តើស្តេចខ្មែរ គឺសម្តេច **នរោត្តម** ទ្រង់បានហៅបារាំងអោយមកគ្រប់គ្រងស្រុកខ្មែរឬក៏បារាំង បានមកបង្ខំអោយព្រះអង្គទទួលយកអាណាព្យាបាលភាពរបស់បារាំង ?

បើតាមឯកសារសៀម (8-49) គេបានអះអាងថាបារាំងបានបង្ខំអោយសម្តេច **នរោត្តម** ធ្វើសន្ធិសញ្ញាដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលភាពបារាំង ប៉ុន្តែខាងបារាំងបានប្រកែកថា ពុំបានធ្វើការកៀបសង្កត់អ្វីមួយក្នុងរឿងនោះទេ ព្រោះថាប្រទេសកម្ពុជា ជាប្រទេសឯករាជ្យហើយមានសិទ្ធិធ្វើការចរចាតាមប្រយោជន៍របស់ខ្លួន (48) ។

ដូច្នេះ តើការពិតស្ថិតនៅត្រង់ណា ? យើងនឹងសាកល្បងធ្វើការវិនិច្ឆ័យដោយផ្អែកទៅលើព្រឹត្តិការណ៍ដែលបានកើតឡើង ។

រួចមកហើយ យើងបានឃើញថា **ព្រះហរិរក្សរាមាឥស្សរាធិបតីអង្គឌួង** ទ្រង់មានបំណងចង់ចងស្ពានមេត្រីជាមួយមហាអំណាចអឺរ៉ុបណាមួយមានបារាំងជាដើម ដោយព្រះអង្គមានសង្ឃឹមថា នឹងយកមហិទ្ធិរិទ្ធិរបស់មហាអំណាចនោះមករំដោះប្រទេសព្រះអង្គ អោយរួចពីក្រញាំយួន និងសៀម ប៉ុន្តែកាលណោះបារាំងពុំបានធ្វើអោយព្រះអង្គសំរេចព្រះបំណងបានឡើយ ។

ក្រោយមក ដោយយកលេសថា ស្តេចយួនធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនាជាតិបារាំង ក៏បារាំងបានវាយយកកំពង់ផែ Tourane នៅថ្ងៃទី ១ ខែកញ្ញា ១៨៥៨ រួចវាយកបានបន្ទាយ **ព្រៃនគរ**

នៅថ្ងៃទី ១៧ ខែ កុម្ភៈ ១៨៥៩ ទៀត ។ តាមសន្ធិសញ្ញាចុះថ្ងៃទី ៥ កក្កដា ១៨៦២ ស្ដេច **ទឺឌឹក** បាន ទទួលជាកម្មសិទ្ធិរបស់បារាំងនូវខេត្ត **បៀនហ៊ា - យ៉ា ឌិញ ឌិញទឿង** (មេសរ) និងកោះ **ត្រឡាច** ដែលយួនបានប្រវ័ញ្ចយកពីខ្មែរពីមុនមក ។ លុះបានចូលមកនៅជាអ្នកជិតខាងរបស់ខ្មែរលើដែនដី **កូសាំងស៊ីន** (Cochinchine) ហើយទើបបារាំងបានចាប់អារម្មណ៍យ៉ាងខ្លាំងមកលើប្រទេសខ្មែរ ។ រាជការអាណានិគមនិយមបារាំងជឿថា ទន្លេមេគង្គជាផ្លូវទឹកមួយសំខាន់អាចអោយគេធ្វើការជ្រៀតចូលទៅក្នុងប្រទេសចិនខាងត្បូងបាន ហើយម្យ៉ាងទៀត គេត្រូវរកមធ្យោបាយកំចាត់អោយអស់នូវគ្រោះថ្នាក់ទាំងឡាយដែលគំរាមកំហែងលើអាណានិគមថ្មីរបស់គេ ជាពិសេសគ្រោះថ្នាក់មកពីប្រទេសសៀម ដែលនៅខាងក្រោយនោះមានអធិរាជនៃរាជាណាចក្ររបស់ពួកអង់គ្លេសថែមទៀត ។

គេបានដឹងថា នៅគ.ស.១៨៦១ ក្រោយពីបានវាយបែកបន្ទាយ **ព្រៃនគរ** លោកឧត្ដមនាវី Charner បានបញ្ជូននាយទាហានម្នាក់អោយទៅ **ឧដុង្គ** ដើម្បីធ្វើការទាក់ទងនឹងព្រះរាជាខ្មែរ ដើម្បីទូលប្រាប់ពីជោគជ័យរបស់បារាំងលើទ័ពយួន ពីបំណងរបស់បារាំងចង់តាំងនៅ **កូសាំងស៊ីន** និងពីសេចក្ដីសង្ឃឹមថា នឹងអាចទាក់ទងជាមិត្តភាពជាមួយខ្មែរ ។

ក្រោយមក នៅគ.ស.១៨៦២ លោកឧត្ដមនាវីត្រី Bonard ទេសាភិបាលនៃដែនដី **កូសាំងស៊ីន** បានធ្វើដំណើរមកប្រទេសខ្មែរដោយមានបំណងចង់ស្គាល់ច្បាស់ពីស្ថានភាពប្រទេសនេះ ជាពិសេសពីពួកមន្ត្រីជាបរិវារនៅក្រុង **ឧដុង្គ** ពីសារៈសំខាន់ក្នុងវិស័យកសិកម្ម និងពាណិជ្ជកម្ម ពីទំនាក់ទំនងជាមួយប្រទេសសៀម ។ល ។ លោកទេសាភិបាលក៏បានឆ្លៀតឱកាសនោះសុំចូលគាល់សម្ដេច **នរោត្តម** ដែលបានទទួលលោកយ៉ាងរាក់ទាក់. . . លោកបានទៅទស្សនាប្រាសាទបុរាណនៅតំបន់ **អង្គរ** ហើយធ្វើដំណើរតាមដងទន្លេមេគង្គឡើងរហូតដល់ល្បាក់ទឹក (42) ។

លុះត្រឡប់ទៅ **ព្រៃនគរ** វិញ លោកបានផ្ញើកំណត់មួយទៅជូនលោក Chasseloup Laubat រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក និងអាណានិគម និយាយពីសិទ្ធិរបស់ប្រទេសបារាំងមកលើប្រទេសខ្មែរ ។ បើតាមលោក ប្រទេសបារាំងមានសិទ្ធិលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ព្រោះប្រទេសនេះបានទទួលមត៌កជាសិទ្ធិអធិរាជភាព (droits de suzeraineté) ប្រទេសអាណ្ណាមលើប្រទេសខ្មែរ ដោយមធ្យោបាយវៀចវេរមួយ គឺការបញ្ចូលដែនដី **សាំងស៊ីន** ជាកម្មសិទ្ធិរបស់បារាំង ។ ម្យ៉ាងទៀត លោកទេសាភិបាល Bonard ក៏បានពត៌មានដល់លោក Chasseloup Laubat ពីការប្រាថ្នារបស់សៀមមកលើប្រទេសខ្មែរ ហើយលោកបានសង្កត់លើការចាំបាច់របស់ប្រទេសបារាំងត្រូវតែការពារឯករាជ្យភាពនៃប្រទេសនេះ ដែលមានទាក់ទងទៅនឹងសន្តិសុខនៃដែនដីកូសាំងស៊ីន ។

នៅឆ្នាំបន្ទាប់មកទៀត (១៨៦៣) ក្រោយពីត្រូវបានតែងតាំងជាទេសាភិបាលនៃដែនដីកូសាំងស៊ីនហើយ លោកឧត្តមនាវី de la Grandière បានបញ្ជាអោយលោក អនុនាវីឯក Doudart de Lagrée ធ្វើដំណើរតាមកប៉ាល់ឈ្មោះ **យ៉ាឌីញ** មកធ្វើសង្កេតការណ៍ផ្សេងៗ នៅប្រទេសខ្មែរ ដើម្បីផ្តល់ពត៌មានដ៏ជាក់លាក់ដល់លោកទេសាភិបាល ។

លទ្ធផលនៃបេសកកម្មចុងក្រោយនេះបានបង្ហាញអោយឃើញថា សម្តេច**នរោត្តម** ទ្រង់មានការចងព្រះទ័យល្អទៅលើប្រទេសបារាំង ។ ហើយទោះបីមានបញ្ហាដ៏ស្មុគស្មាញពីលោក Chasseloup Laubat ដែលប្រាថ្នាចង់រំដោះប្រទេសខ្មែរទុកជាប្រទេសទ្រនាប់មួយរវាងប្រទេសសៀម ដែលទទួលឥទ្ធិពលពីអង់គ្លេសនិងដែនដី កូសាំងស៊ីនជាអាណានិគមរបស់បារាំងក៏ដោយ ក៏លោកទេសាភិបាល de la Grangière បានធ្វើដំណើរទៅក្រុង **ឧដុង្គ** នៅខែសីហា ១៨៦៣ ។ បើតាមលោក Moura គឺការជ្រៀតជ្រែករបស់សៀមក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរនោះហើយ ដែលជាមូលហេតុញ៉ាំងលោកទេសាភិបាលអោយទៅគាល់ព្រះរាជាខ្មែរក្នុងពេលនោះ ព្រោះបារាំងបានសង្កេតឃើញថា គឺតំណាងសៀមនៅអមព្រះរាជាខ្មែរនោះទេ ជាព្រះរាជាខ្មែរពិតប្រាកដ ។ ដូច្នេះ គឺដើម្បីកំចាត់អោយអស់នូវឧបាយសម្ងាត់ទាំងឡាយរបស់សៀមដែលអាចគំរាមកំហែងដល់ជំហររបស់បារាំងនៅឥណ្ឌូចិន ដើម្បីបង្កើតអោយមានសន្តិសុខនៅព្រំដែននៃអាណានិគមថ្មី និងដើម្បីត្រួតពិនិត្យមើលនូវដែនដីខាងក្នុងមួយដែលផ្តល់ប្រយោជន៍ច្រើនដែលបារាំងបានតាំងអាណាព្យាបាលភាពរបស់ខ្លួនលើប្រទេសខ្មែរ ។ លោកទេសាភិបាល de la Grandière បានទទួលហេតុផលទាំងនោះយ៉ាងសព្វគ្រប់ដល់ព្រះរាជាខ្មែរ ហើយសូមព្រះអង្គព្រមដាក់ប្រទេសខ្មែរអោយបារាំងជួយការពារ ។ សម្តេច Miche ទ្រង់បានថ្វាយនូវគំរោងសន្ធិសញ្ញាមួយ ហើយទ្រង់បានធ្វើការពិភាក្សាជាមួយព្រះរាជាខ្មែរ ហើយនៅថ្ងៃទី ១១ សីហា ១៨៦៣ លោក de la Grandière បានចុះហត្ថលេខាក្នុងនាមលោកផ្ទាល់ លើសន្ធិសញ្ញាមិត្តភាព ការការពារ និងពាណិជ្ជកម្មមួយជាមួយសម្តេច **នរោត្តម** ដែលបានទទួលយល់ព្រមដោយមានការញញើតញញើមយ៉ាងច្រើន (4) ។

ដូច្នេះយើងឃើញថា ព្រះបាទ**នរោត្តម** ពុំបានហៅបារាំងអោយមកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរទេ ហើយព្រះអង្គទ្រង់បានទទួលយកសន្ធិសញ្ញាថ្ងៃ ១១ ខែសីហា ១៨៦៣ នោះ គឺទំនងជាមានការ **គៀបសង្កត់ដោយមិត្តភាព** ពីសំណាក់លោកទេសាភិបាល de la Grandière ជាមិនខាន ។ ភស្តុតាងមួយដ៏ជាក់ស្តែងក្នុងរឿងនេះគឺសារលិខិតមួយដែលព្រះអង្គទ្រង់បានផ្ញើទៅថ្វាយព្រះចៅសៀមក្រោយពេលដែលព្រះអង្គបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាខាងលើ ។ ក្នុងសារលិខិតនោះព្រះអង្គទ្រង់បានត្អូញត្អែរថា ព្រះអង្គត្រូវគេបង្ខំអោយធ្វើសន្ធិសញ្ញាជាមួយបារាំង ។

តើមានអ្វីខ្លះជា ខសំខាន់ក្នុងសន្ធិសញ្ញាចុះថ្ងៃទី ១១ ខែ សីហា ១៨៦៣ ?

ក្នុងមាត្រាទី ១ មានសេចក្តីចែងថា ព្រះចៅអធិរាជនៃជនជាតិបារាំងនឹងផ្តល់នូវការការពារដល់ព្រះរាជាខ្មែរ ។ ក្នុងមាត្រាបន្តបន្ទាប់មកទៀតមានចែងថា ព្រះចៅនៃជនជាតិបារាំងនឹងតែងតាំងរេស៊ីដង់ម្នាក់ដែលមានឋានៈជាមន្ត្រីជាន់ខ្ពស់អោយនៅអម ព្រះរាជាខ្មែរ ឯព្រះរាជាខ្មែរនឹងតែងតាំរេស៊ីដង់ខ្មែរម្នាក់អោយនៅអមលោកទេសាភិបាលនៃដែនដីកូសាំងស៊ីនវិញ ។ ប៉ុន្តែបើមានការតែងតាំងកុងស៊ុលដទៃក្រៅពីប្រទេសបារាំង នោះតម្រូវអោយមានការយល់ព្រមពីលោកទេសាភិបាលកូសាំងស៊ីនផងដែរ ។

ជនជាតិបារាំងដែលមករស់នៅលើទឹកដីខ្មែរក្តី ជានជាតិខ្មែរដែលទៅរស់នៅក្នុងអធិរាជាណាចក្របារាំងក្តី សុទ្ធតែមានសេរីភាពពេញលេញក្នុងការទៅមក និងក្នុងការរស់នៅអោយតែជនទាំងនោះបានទៅសុំចុះឈ្មោះច្បាប់អនុញ្ញាតពីរេស៊ីដង់របស់ខ្លួន ។ លោករេស៊ីដង់បារាំងមានសិទ្ធិជុំនំជំរះវិវាទដែលបានកើតឡើងរវាងជនជាតិបារាំង និងជនជាតិអឺរ៉ុបដទៃទៀត ។ ក្នុងករណីមានជម្លោះរវាងជនជាតិបារាំង និងជនជាតិខ្មែរវិញនោះនឹងមានមន្ត្រីខ្មែរម្នាក់នៅអមលោករេស៊ីដង់បារាំងក្នុងការជំនុំជំរះ ។

កប៉ាល់របស់បារាំងមានសេរីភាពពេញលេញក្នុងការធ្វើជំនួញក្នុងដែនទឹកខ្មែរ ដោយមិនបាច់បង់ពន្ធគយអ្វីទាំងអស់ លើកលែងតែពន្ធលើអាភៀនចេញ ។ ឯកប៉ាល់ខ្មែរវិញក៏មានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើជំនួញក្នុងកំពង់ផែទាំងឡាយនៃដែនកូសាំងស៊ីនវិញដែរ ។

រដ្ឋាភិបាលខ្មែរត្រូវសន្យាថា ការពារពួកអ្នកផ្សាយសាសនា ពួកអ្នកប្រាជ្ញបារាំង និងជនជាតិបារាំងជាទូទៅដែលរស់នៅ ឬដែលធ្វើជំនួញក្នុងទឹកដីខ្មែរ ។ ចំណែកឯជនជាតិខ្មែរដែលរស់នៅ ឬធ្វើជំនួញក្នុងទឹកដីកម្មសិទ្ធិរបស់បារាំង ក៏នឹងត្រូវបានទេសាភិបាលនៃទឹកដីនោះការពារវិញដែរ ។

ព្រះចៅអធិរាជនៃជនជាតិបារាំងសន្យាថា នឹងរៀបចំអោយប្រទេសកម្ពុជាបានស្ថិតក្នុងសន្តិភាព និងរបៀបរៀបរយ និងការពារចំពោះការវាយលុកទាំងឡាយមកពីខាងក្រៅនឹងជួយខ្មែរក្នុងការហូតពន្ធគយ និងផ្តល់គ្រប់ភាពងាយស្រួលក្នុងការធ្វើគមនាគមន៍ជាមួយនឹងសមុទ្រ ។

ជាថ្នូរវិញ ប្រទេសកម្ពុជាព្រមអោយជាសម្បទានដល់ប្រទេសបារាំងនូវដីម្តុំត្រង់ជ្រោយចង្វាដើម្បីស្ថាបនាឃ្លាំងផ្ទុកធ្យូង ឃ្លាំងសំរាប់ផ្តល់ស្បៀងដល់កប៉ាល់បារាំង និងបន្ទាយសំរាប់អោយទាហាននៅ ។ ពិសេសទៅទៀត ដើម្បីជាការដឹងគុណចំពោះប្រទេសបារាំង ដែលបានផ្តល់នូវការការពារដល់ប្រទេសកម្ពុជា ខ្មែរត្រូវបើកសិទ្ធិអោយបារាំងកាប់ឈើក្នុងព្រៃទាំងឡាយក្នុងព្រះរាជាណាចក្រ ដើម្បីយកទៅស្ថាបនាកប៉ាល់ ។

សរុបសេចក្តីមក យើងឃើញថាទោះបីខាងគូភាគីខ្មែរចាញ់ប្រៀបខាងគូភាគីបារាំងខ្លះក៏ដោយ ក៏មានមតិភាគច្រើនយល់ឃើញថា ខ្មែរអាចទទួលយកសន្ធិសញ្ញាថ្ងៃ១១ ខែសីហា ១៨៦៣ ព្រោះបារាំងពុំបានដកហូតអំណាចពីព្រះរាជាខ្មែរនៅឡើយ ។ ប៉ុន្តែ ទោះបីបារាំងបានសន្យាថានឹងការពារប្រទេសកម្ពុជាប្រឆាំងនឹងអំពើវាយលុកពីក្រៅក៏ដោយ ក៏ព្រះបាទ **នរោត្តម** ទ្រង់បានធ្វើសន្ធិសញ្ញាសម្ងាត់មួយ

ជាមួយព្រះចៅសៀមចុះថ្ងៃទី១ ខែធ្នូ ១៨៦៣ ដោយទទួលស្គាល់ថាប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀមដដែល និងដោយព្រមលះបង់អោយប្រទេសសៀមនូវខេត្តបាត់ដំបង អង្គរ មង្គលបុរី ស៊ីសុផុន កំពង់ស្វាយ និងពោធិ៍សាត់ (48) ។ គួរគប្បីជ្រាបថា សន្ធិសញ្ញាសម្ងាត់នេះ បានធ្វើឡើងក្នុងពេលដែលសន្ធិសញ្ញា ថ្ងៃ១១ ខែសីហា ១៨៦៣ ត្រូវផ្ញើទៅប្រទេសបារាំងសុំសច្ចាប័នពីព្រះចៅ Napoléon ទី ៣ ។ ប៉ុន្តែ លុះបានទទួលសន្ធិសញ្ញាដែលមានសច្ចាប័នពីព្រះចៅ Napoléon ទី ៣ ហើយលោកទេសាភិបាលនៅកូសាំងស៊ីនបានតម្រូវអោយព្រះចៅសៀមបញ្ជូនគ្រឿងសំរាប់រាជ្យមក **ឧដុង្គ** យ៉ាងឆាប់រហ័សដើម្បីធ្វើពិធីអភិសេកព្រះបាទ **នរោត្តម** នៅថ្ងៃទី៣ ខែមិថុនា ១៨៦៤ ។ បន្ទាប់ពីនោះ រាជទូតសៀមត្រូវចាកចេញពីក្រុង**ឧដុង្គ** ហើយព្រះចៅសៀមក៏អស់អំណាចគ្រប់គ្រងមកលើប្រទេសខ្មែរចាប់តាំងពីពេលនោះដែរ ។

## ៥. ការតស៊ូរបស់លោកអាចារ្យស្វា និងលោកពោធិកំបោរ

ទោះបីសន្ធិសញ្ញាថ្ងៃ១១ ខែសីហា ១៨៦៣ ដែលស្ថិតលើបដិការ (réciprocité) ក្នុងការផ្តល់ប្រយោជន៍អោយគ្នាទៅវិញទៅមកក៏ដោយ ក៏មានអ្នកស្នេហាជាតិបានក្រោកឈរកាន់អាវុធប្រឆាំងនឹងការប៉ុនប៉ងរបស់បារាំងក្នុងការត្រួតត្រាប្រទេសខ្មែរដែរ ។

គួរគប្បីជ្រាបថា បើតាមឯកសារបារាំង ឬតាមទស្សនៈរបស់អ្នកប្រវត្តិសាស្ត្របារាំងភាគច្រើន គេពុំបានចាត់ទុកថាលោក **អាចារ្យស្វា** និងលោក **ពោធិកំបោរ** ជាវីរជនស្នេហាជាតិទេ តែគេនិយមទុកថាជាមេចោរ ជាជនបោកប្រាស់ (51) ជាមេឧទ្ទាមទៅវិញ (9) ។

មានអ្នកប្រវត្តិសាស្ត្រខ្លះទៀតបានយល់ឃើញថា ការតស៊ូរបស់លោក **អាចារ្យស្វា** និង **ពោធិកំបោរ** គឺបណ្តាលមកពីជម្លោះរាជវង្សវិញ ព្រោះគេបានឃើញថា**លោក អាចារ្យស្វា បានតាំងខ្លួនលោកជា អង្គគីម** ដែលត្រូវជារាជបុត្ររបស់ព្រះ **អង្គអិម** ឯ **ពោធិកំបោរ** បានតាំងខ្លួនថាជាចៅរបស់ព្រះ**អង្គចន្ទ** ។ ប៉ុន្តែ មានមតិខ្លះយល់ថា ការតាំងខ្លួនដូច្នេះគឺគ្មានបំណងអ្វីក្រៅពីទាក់ទាញអោយប្រជារាស្ត្រចុះចូលអោយបានច្រើន គឺថាធ្វើស្របទៅតាមចិត្តគំនិតរបស់ខ្មែរក្នុងសម័យនោះដែលនៅគោរពបូជាស្តេចថាជាអាទិទេពនៅឡើយ (48) ។

បើតាមឯកសារខ្មែរ (52) និងតាមពាក្យដំណាលតៗមក លោក **អាចារ្យស្វា** នេះ ជាខ្ញុំបំរើរបស់នាម៉ឺនម្នាក់នៅរាជធានី **ឧដុង្គ** ។លុះបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរនៅគ.ស.១៨៦៤ លោក **អាចារ្យស្វា**បានភៀសទៅកទ័ពវាយយកបានខេត្ត **ត្រាំង** ហើយលើកឆ្ពោះមកក្រុងភ្នំពេញទៀត ។ ប៉ុន្តែ លោកត្រូវវាយថយចូលទៅនៅខេត្ត **មាត់ជ្រូក** ។ តាមសំណូមពររបស់លោក Doudart de Lagrée លោក Roze ជាទេសាភិបាលនៃកូសាំងស៊ីន បានធ្វើអន្តរាគមន៍ដោយសុំអោយអាជ្ញាធរយួនប្រគល់ខ្លួន

លោក **អាចារ្យស្វា** អោយទៅបារាំង ។ ក្រោយមកលោក Doudart de Lagrée និងលោកអនុសេនីយឯក Obry បានធ្វើប្រតិបត្តិការសឹកដេញតាមចាប់លោកនៅថ្ងៃទី ១៩ ខែសីហា ១៨៦៦ ។ លោកត្រូវបារាំងនិរទេសយកទៅដាក់នៅកោះត្រឡាច រួចនៅកោះ la Réunion ហើយនៅទីបំផុតនៅកោះ Antilles ។

ចំណែកឯលោក **ពោធិកំបោរ** ជាព្រះសង្ឃមួយអង្គមានដើមកំណើតនៅខេត្ត **ពេជ្រដីរ** ។ នៅ គ.ស. ១៨៦៥ លោកទេសាភិបាល de la Grandière និងលោក Roze បានផ្តល់មធ្យោបាយជាលុយកាក់អោយលោករស់នៅ **ព្រៃនគរ** ទំនងជាដើម្បីស្រួលឃ្លាំមើលសកម្មភាពរបស់លោកតែប៉ុណ្ណោះ ។ នៅខែ ឧសភា ១៨៦៦ លោកបានភៀសចូលទៅក្នុងខេត្ត **ពេជ្រដីរ** ហើយកទ័ពនៅទីនោះ ។ នៅខែក្រោយមេទាហានបារាំងពីរនាក់ត្រូវអ្នកស្នេហាជាតិខ្មែរសម្លាប់ ។ ទ័ពបារាំងនៅព្រៃនគរបានលើកទៅបំរុងនឹងកំចាត់លោក ។ លោកក៏ឆ្លងចូលទៅក្នុងប្រទេសខ្មែរហើយនៅខែធ្នូ ១៨៦៦ លោកបានលើកទ័ពឆ្ពោះទៅរាជធានី **ឧដុង្គ** និង **ភ្នំពេញ** ។ បារាំងបានសុំជំនួយទ័ពពីក្រសួងទ័ពជើងទឹក និងអាណានិគម ហើយធ្វើអន្តរាគមន៍ការពារក្រុងទាំងពីរនេះ ។ ប៉ុន្តែ នៅខែមករា ១៨៦៧ ស្ថានភាពសឹក និងនយោបាយនៅប្រទេសខ្មែរកាន់តែតឹងតែងឡើង : រាស្ត្រក្រោកឈរប្រឆាំងបារាំងគ្រប់ទីកន្លែង ។

នៅថ្ងៃទី ៩ ខែ មករា ១៨៦៧ បារាំងសុំជំនួយទ័ព និងថវិកាថែមទៀត ។ នៅខែ កុម្ភៈ និងមិនាឆ្នាំដដែល ទ័ពបារាំងវាយឈ្នះទ័ពលោក **ពោធិកំបោរ** នៅ **ឧដុង្គ** ។ លោកដកថយទៅនៅខេត្ត **កំពង់ស្វាយ** តែបារាំងដេញតាមចាប់លោក លោកក៏ថយទៅខាងជើងទៀត ។

គួរគប្បីជ្រាបថា នៅខែ មិថុនា ១៨៦៧ ខេត្តទាំង៣ គឺ **លង់ហោរ មាត់ជ្រូក** និង **ពាម** ដែលយួនបានយកពីខ្មែរនោះ ត្រូវបារាំងវាយយកបញ្ចូលជាអាណានិគមកូសាំងស៊ីនរបស់ខ្លួនទៀត ព្រោះខេត្តទាំង៣ នោះជាទីតាំងរបស់ពួកយួនដែលប្រឆាំងបារាំង និងជួយគាំទ្រពួកអ្នកស្នេហាជាតិខ្មែរក្នុងការប្រឆាំងបារាំងដូចខ្លួនដែរ ។ នៅពេលនោះលោក **ពោធិកំបោរ** បានធ្វើសកម្មភាពជាថ្មីនៅខាងជើងខេត្ត **ពេជ្រដីរ** និងនៅតំបន់ **ធាត្នំ** ។ ប៉ុន្តែលោកត្រូវទ័ពរបស់ព្រះ **កែវហ្វាស៊ីសុខត្តិ** រុញច្រានអោយភៀសទៅទិសប្រទេសលាវ ហើយគេសម្លាប់លោកបានក្នុងពេលភៀសខ្លួននោះនៅថ្ងៃទី៣០ ខែវិច្ឆិកា ១៨៦៧ ។ មានឯកសារខ្លះថា លោកត្រូវគេសម្លាប់នៅខែធ្នូ (70) ហើយគឺរាស្ត្រដែលធ្លើយណាយនឹងការជិះជាន់របស់លោកនេះឯងដែលបានសម្លាប់លោក (9) ។

គួរគប្បីជ្រាបម្យ៉ាងទៀតថា នៅពេលដំណាលៗគ្នានោះគឺ នៅថ្ងៃ១៥ កក្កដា ១៨៦៧ ព្រះចៅសៀម និងព្រះចៅអធិរាជនៃជនជាតិបារាំង បានធ្វើសន្ធិសញ្ញាមួយជាមួយគ្នា ។ តាមរយៈសន្ធិសញ្ញានេះព្រះចៅសៀមទ្រង់ទទួលស្គាល់ជាឧឡារិកនូវអាណាព្យាបាលភាពរបស់បារាំងមកលើប្រទេសកម្ពុជា ។ ចំណែកខាងបារាំងបានសន្យាថា មិនវាយយកប្រទេសនេះទៅបញ្ចូលជាមួយអាណានិគមកូសាំងស៊ីន

របស់ខ្លួន ហើយត្រូវទទួលស្គាល់ថាខេត្ត **បាត់ដំបង អង្គរ** និង **ស៊ីសុផុន** ជាកម្មសិទ្ធិរបស់សៀមជាស្ថាពរ ។

គឺនៅឆ្នាំ ១៨៦៧ ដដែលនេះដែរដែលព្រះបាទ**នរោត្តម**ទ្រង់បានលើករាជធានីពី **ឧដុង្គ** ទៅតាំងនៅក្រុង **ភ្នំពេញ** វិញ ។

## ៦. ការកែទំរង់ជាលើកដំបូង

នៅគ.ស.១៨៧០ ព្រះ**កែវហ្វាស៊ីសុវត្ថិ** ព្រះអនុជព្រះបាទ **នរោត្តម** បានយាងពី **ព្រៃនគរ** ចូលប្រទេសខ្មែរវិញ ហើយត្រូវបានតាំងជាមហាឧបរាជ ។

នៅគ.ស.១៨៧៦ ព្រះ **អង្គស៊ីវត្ថា** ដែលភៀសទៅសៀមពីមុនបានត្រឡប់ចូលស្រុកវិញ ហើយបំបះបំបោររាស្ត្រម្តងទៀតនៅត្រង់ **បាភ្នំ រំដួល ព្រៃវែង** ។ តាមរាជពង្សាវតារខ្មែរ ថានេះជាឧបាយកលថ្មីមួយទៀតរបស់សៀមដែលបានគិតថា បើបានបារាំងទំនុកបំរុងយូរទៅ មុខជាទាមទារយកទឹកដីដែលសៀមបានយករួចហើយទើបសៀមអោយព្រះ**អង្គស៊ីវត្ថា** មកច្បាំងដណ្តើមរាជ្យ ។ លើកនេះទៀតព្រះមហាឧបរាជ **ស៊ីសុវត្ថិ** ត្រូវចាត់អោយចេញបង្ក្រាបបានរាបទាបវិញដោយមានជំនួយពីទ័ពបារាំងផង ។

លុះបានសន្តិភាពឡើងវិញ ហើយក្រោយពីបានធ្វើទស្សនកិច្ចនៅក្រុងខ្លះដូចជា **ហុងកុង ម៉ាកាវ គង់តុង** និង **ម៉ានីល**(១៨៧២) ដើម្បីទ្រង់ជ្រាបពីវឌ្ឍនភាពក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច នៅភូមិភាគអាស៊ីអាគ្នេយ៍ ដោយសារបច្ចេកទេសរបស់អ្នកគ្រប់គ្រង ពួកឈ្មួញ និងពួកអ្នកជំនួញខាងហិរញ្ញវត្ថុជាតិអឺរ៉ុប និងក្រោយពីបានធ្វើការចរចាជាច្រើនលើកជាមួយអ្នកតំណាងប្រទេសបារាំង ទើបព្រះបាទ **នរោត្តម** ទ្រង់បានសំរេចព្រះទ័យ ថាត្រូវតែធ្វើការកែទំរង់តាមព្រះរាជបញ្ញត្តិចុះថ្ងៃទី១៥ ខែមករា ១៨៧៧ ដើម្បីអោយប្រទេសជាតិបានចំរើនលូតលាស់ទាន់សម័យនឹងគេ ។

### *- បញ្ញត្តិទាក់ទងនឹងរាជវង្សានុវង្ស*

បញ្ញត្តិនេះបានសំរេចចោលនូវឋានៈជាឧភយោរាជ ឧបរាជ និងវររាជជិនីព្រមទាំងមន្ត្រីទាំង ៣ សំរាប់នៃក្សត្រទាំង ៣ នេះ ក្រោយពេលដែលក្សត្រក្នុងឋានៈនេះសោយទិវង្គតទៅ ។ ប្រាក់បៀវត្សនៃក្សត្រា - ក្សត្រីក្នុងរាជវង្សានុវង្សត្រូវបានតម្លើងដើម្បីអោយក្សត្រទាំងនោះអាចមានជីវភាពរស់នៅដោយសមរម្យផង ។ ឯប្រាក់ចំណូលមួយភាគធំត្រូវយកទៅចាយក្នុងកិច្ចការជាប្រយោជន៍រួមវិញ ។

ព្រះមហាក្សត្រិយ៍ ទ្រង់គង់នៅជាម្ចាស់នៃដីទាំងឡាយក្នុងព្រះរាជាណាចក្រ ប៉ុន្តែព្រះអង្គទ្រង់បានសន្យាថា នឹងពន្យាររយៈពេលនៃការជួលដីសំរាប់ធ្វើស្រែចំការអោយបានវែងជាងមុន ។

- ***បញ្ញត្តិទាក់ទងនឹងរដ្ឋាភិបាល***

មានការបង្កើត **ក្រុមប្រឹក្សា** មួយដែលមានមន្ត្រីជាន់ខ្ពស់ ៥ នាក់ (រដ្ឋមន្ត្រី) ដែលអាចពិភាក្សាកិច្ចការរដ្ឋ ដោយគ្មានវត្តមានរបស់ព្រះរាជា ។ ក្រុមប្រឹក្សានេះត្រូវទទួលភារៈត្រួតពិនិត្យមើលការអនុវត្តច្បាប់ សិក្សាពីការកែទំរង់ចាំបាច់ដែលត្រូវធ្វើ និងពិនិត្យមើលនូវកិច្ចព្រមព្រៀងទាំងឡាយរវាងរដ្ឋាភិបាល និងជនទាំងឡាយណាដែលចង់ធ្វើអាជីវកម្មអ្វីមួយក្នុងរាជាណាចក្រ ។

- ***បញ្ញត្តិទាក់ទងនឹងរដ្ឋាភិបាល***

ទឹកដីខ្មែរទាំងមូលត្រូវបែងចែកជា **មណ្ឌលរដ្ឋបាល** ធំៗប្រាំ តាមចំនួននៃរដ្ឋមន្ត្រីទាំងប្រាំ ដែលត្រូវគ្រប់គ្រងមណ្ឌលនិមួយៗ ។ ចំនួនខេត្តត្រូវបង្រួញពី ៥៧មកនៅត្រឹម ៥០វិញ ។ អំណើះតទៅពួកនាម៉ឺនត្រូវទទួលប្រាក់បៀរវត្សដែលមានកំរិតជាក់លាក់ ហើយត្រូវហាមឃាត់មិនអោយធ្វើជំនួញ ។ ពួកឧកញ៉ាហ្លួងដែលមានភារៈទៅត្រួតមើលខេត្តនានាត្រូវលប់ចោល ព្រោះពួកនេះបានទាញយកផលប្រយោជន៍ពីព្រះរាជាផង និងពីប្រជារាស្ត្រផង (53) ។ ម្យ៉ាងទៀត ប្រជារាស្ត្រមានសិទ្ធិជ្រើសរើស **មេស្រុក មេឃុំ** និង **ជំទប់** របស់ខ្លួន ។

- ***បញ្ញត្តិទាក់ទងនឹងពន្ធដា***

គេបានលប់ចោលនូវរបបទារពន្ធតាមភាសី លើកលែងតែភាសីខាងអាភៀន និងស្រាចេញ ។ ម្យ៉ាងទៀតពន្ធមួយចំនួនក៏ត្រូវគេលប់ចោលដែរ ជាពិសេសពន្ធលើល្បែងស៊ីសងដែលត្រូវហាមឃាត់ក្នុងសម័យនោះ ។ កំណែនអោយធ្វើការជូនរដ្ឋត្រូវរក្សាទុកនៅដដែល ប៉ុន្តែថេរវេលាត្រូវបន្ថយមកនៅត្រឹម ៩០ថ្ងៃក្នុង ១ឆ្នាំ ហើយដែលគេអាចយកប្រាក់ទៅលោះបាន ។ ពន្ធលើផលិតផលកសិកម្មខ្លះដូចជា ម្លូ ម្រេច ស្ករ ត្រូវបានបន្ធូរបន្ថយ (53) ។

- ***បញ្ញត្តិទាក់ទងនឹងតុលាការ***

មានការគ្រោងបង្កើតនូវតុលាការជាន់ខ្ពស់មួយ ដែលមានមុខងារជាសាលាឧទ្ធរណ៍ ។ ពួកមន្ត្រីដែលទទួលសំណូកពីគូក្តីត្រូវទទួលទណ្ឌកម្មជាទម្ងន់ ។ ប្រាក់ពិន័យលែងបានទៅពួកចៅក្រមទៀតហើយ ។ មន្ត្រីប្រភេទនេះត្រូវទទួលប្រាក់បៀវត្សដែលមានកំរិតជាក់លាក់ ដូចមន្ត្រីឯទៀតៗដែរ ។ ជីវភាពរបស់ពួកជនជាប់គុកត្រូវបានរៀបចំអោយបានប្រសើរជាងមុន ។

- ***បញ្ញត្តិទាក់ទងនឹងទាសភាព***

ពួកទាសាទាសីដែលត្រូវទៅនៅបំរើម្ចាស់បំណុលអស់មួយជីវិតពីមុននោះ អាចលោះខ្លួនអោយរួចពីខ្ញុំគេបាន ។ ការលក់ដូរពួកមនុស្សព្រៃ និងកូនក្មេងត្រូវហាមឃាត់ ។

ក្រៅពីបញ្ញត្តិចុះថ្ងៃទី ១៥ ខែមករា ១៨៧៧នេះ គួរកត់សំគាល់ថានៅមានអនុសញ្ញាមួយចុះថ្ងៃទី ២៨ ខែមករា ឆ្នាំដដែល ហើយដែលធ្វើឡើងរវាងព្រះបាទ **នរោត្តម** និងលោកទេសាភិបាលកូសាំងស៊ីន ។ អនុសញ្ញានេះ បានបើកអំណាចយ៉ាងទូលាយថែមទៀតដល់តំណាងប្រទេសបារាំងនៅអមព្រះរាជាខ្មែរ ដោយអនុញ្ញាតអោយលោកចូលរួមក្នុងកិច្ចប្រជុំទាំងឡាយរបស់គណៈរដ្ឋមន្ត្រី ដើម្បីផ្តល់យោបល់ផ្សេងៗបាន ។ ក្នុងករណីណាដែលមានបញ្ហាសំខាន់ៗត្រូវដោះស្រាយនោះ វត្តមានរបស់តំណាងប្រទេសបារាំងជាការចាំបាច់ ។

## ៧. អនុសញ្ញាថ្ងៃទី ១៧ មិថុនា ១៨៨៤ និងផលវិបាក

គួរគប្បីជ្រាបថា គំរោងនៃការកែទំរង់ទាំងប៉ុន្មានដូចបានរៀបរាប់រួចមកហើយពុំបានទទួលជោគជ័យទាំងអស់ទេ ។ ផ្ទុយទៅវិញការអនុវត្តត្រូវជួបប្រទះនឹងឧបសគ្គជាច្រើន បណ្តាលមកពីប្រតិកម្មមិនអនុគ្រោះពីសំណាក់ពួកមន្ត្រីជាច្រើន និងពួកមេបំណុល ។

រដ្ឋាភិបាលបារាំងដោយបានទទួលរបាយការណ៍លំអៀង ក៏មានការមន្ទិលសង្ស័យទៅលើព្រះសុឆន្ទៈរបស់ព្រះរាជា ។ នៅពេលនោះលោក Jules Ferry ដែលកាន់តំណែងជានាយករដ្ឋមន្ត្រី បានសំរេចថាត្រូវតែតាំងអាណាព្យាបាលភាពពិតប្រាកដលើប្រទេសខ្មែរ ជាជំនួសការការពារដែលមានតាំងពីមុនមក ។ លោកបានប្រគល់បន្ទុកនេះអោយទៅលោក Charles Thomson ទេសាភិបាលដែនកូសាំងស៊ីន (9) ។

ឯកសារជាច្រើន ជាពិសេសសៀវភៅរបស់លោក Paul Collard បានបញ្ជាក់ថាការតាំងអាណាព្យាបាលភាពរបស់បារាំងនៅលើកនេះគឺធ្វើដោយបង្ខិតបង្ខំ ដោយគំរាមកំហែងយ៉ាងជាក់ស្តែងតែម្តង ។

យ៉ាងណាមិញ លោក Charles Thomson បានយកកប៉ាល់ចំបាំងទៅឡោមព័ទ្ធវាំង បានលុកចូលក្នុងក្រឡាបន្ទំក្នុងពេលដែលព្រះរាជាកំពុងតែផ្ទុំ ហើយបង្ខំអោយព្រះអង្គចុះព្រះហស្តលេខាលើអនុសញ្ញាមួយដែលបានដកហូតអំណាចទាំងឡាយរបស់ព្រះអង្គ នៅថ្ងៃទី ១៧ ខែមិថុនា ១៨៨៤ ។

មាត្រាទី ១ បានបង្ខំអោយព្រះរាជាទទួលស្គាល់ជាមុននូវ **ការកែទំរង់** ទាំងឡាយខាងផ្នែករដ្ឋបាល ផ្នែកតុលាការ ផ្នែកហិរញ្ញវត្ថុ និងផ្នែកពាណិជ្ជកម្ម ដែលសាធារណរដ្ឋបារាំងយល់ថាគួរតែធ្វើក្នុងអនាគតកាល ។

មាត្រាទី ៣ ចែងថា ក្នុងការគ្រប់គ្រងខេត្ត និងក្រសួងនានាមន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំង ។ ចំណែកឯក្រសួងគយ ក្រសួងពន្ធដា ក្រសួងសាធារណការ និងក្រសួងឯទៀតដែលមានប្រើវិស្វករត្រូវបានបារាំងកាន់កាប់ផ្ទាល់តែម្តង ។

មាត្រាទី ៤ និងទី ៥ ចែងថា រដ្ឋាភិបាលបារាំងអាចតែងតាំង **រេស៊ីដង់** និង**រេស៊ីដង់រង** អោយត្រួតពិនិត្យមន្ត្រីខ្មែរនៅតាមទីរួមខេត្ត និងនៅគ្រប់ទីកន្លែងណាដែលគេយល់ថាគួរដាក់ ។ មន្ត្រីបារាំងទាំងនោះស្ថិតនៅក្រោមឱវាទរបស់ **រេស៊ីដង់ជាន់ខ្ពស់** ម្នាក់ដែលអាចសុំធ្វើសវនាការជាមួយព្រះរាជាបានជានិច្ច ។

មាត្រាទី ៦ ចែងថាចំណាយទាំងឡាយរបស់រដ្ឋការខ្មែរ និងរបស់រដ្ឋការអាណាព្យាបាលបារាំងជាបន្ទុករបស់ប្រទេសកម្ពុជា ។

មាត្រា ៧ ចែងថាអំណើះតទៅព្រះរាជាត្រូវទទួលប្រាក់បៀវត្សដែលមានកំរិតជាក់លាក់ ហើយមិនអាចខ្ចីប្រាក់ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលបារាំងឡើយ ។

មាត្រា៩ ចែងថាដីធ្លីក្នុងព្រះរាជាណាចក្រទាំងមូលពីដើមជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះរាជា ឥឡូវពួកអាជ្ញាធរបារាំង និងខ្មែរអាចរៀបចំអោយមានកម្មសិទ្ធិឯកជនខាងដីធ្លីនេះបាន ។

មាត្រា១០ ចែងថាក្រុងភ្នំពេញត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ អមដោយក្រុមប្រឹក្សាមួយមានសមាជិកជាតិបារាំង ៦នាក់ ជនបរទេស ៤នាក់ និងខ្មែរ ៣នាក់ ។

សេចក្តីជាខសំខាន់ដែលបានលាតត្រដាងក្នុងមាត្រាទាំងប៉ុន្មានខាងលើនេះបានបង្ហាញអោយឃើញថា រដ្ឋការបារាំងបានកាន់កាប់អំណាចសឹងទាំងស្រុងក្នុងការគ្រប់គ្រងប្រទេសកម្ពុជា ។ ម្ល៉ោះហើយទោះបីត្រូវគេបង្ខំអោយទទួលយក **អនុសញ្ញា ថ្ងៃទី ១៧ ខែមិថុនា ១៨៨៤** ក៏ដោយ ក៏ព្រះបាទ **នរោត្តម** ទ្រង់បានរកមធ្យោបាយដើម្បីរំដោះប្រទេសព្រះអង្គអោយរួចពីការត្រួតត្រាផ្ទាល់របស់បរទេសវិញដែរ ។

ចំពោះរឿងនេះ លោក Paul Collard បានសរសេរថា : "គ្រាន់តែសភារបស់បារាំងបានអោយសច្ចាប័នលើអនុសញ្ញា ហើយគ្រាន់តែសច្ចាប័ននោះបានថ្វាយដល់ព្រះរាជាជ្រាបភ្លាម ក៏ប៉ុស្តិ៍បារាំងត្រូវវាយលុកនៅគ្រប់ទិសទី ។ នៅថ្ងៃទី ៦ ឧសភា ១៨៨៥ រាជធានីត្រូវវាយលុកដោយពួកឧទ្ទាម ៥០០០ នាក់ប្រដាប់ដោយព្រួញ និងកាំភ្លើងបាញ់ថ្ម... " ។

ដូច្នេះ យើងឃើញថា **អនុសញ្ញា ថ្ងៃទី ១៧ ខែមិថុនា ១៨៨៤** បានបណ្តាលអោយមានប្រតិកម្មយ៉ាងខ្លាំងក្លាពីសំណាក់ប្រជារាស្ត្រខ្មែរ ហើយពួកមន្ត្រីបារាំងភាគច្រើនបានយល់ថា គឺព្រះបាទ **នរោត្តម** នេះហើយជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងបារាំងនេះឯង ។ លោក Paul Collard បានសរសេរថា " មុនអ្វីទាំងអស់ព្រះអង្គ (ព្រះបាទនរោត្តម)នឹងផ្តើមធ្វើសង្គ្រាម ព្រោះព្រះអង្គមិនទាន់អស់សង្ឃឹមទេ ។ ក៏ប៉ុន្តែដោយឡប់ស្មារតីបណ្តាលមកពីអត្ថបទនៃអនុសញ្ញាដែលបានបង្ហាញចំពោះព្រះអង្គនូវអាកប្បកិរិយារឹងប៉ឹងរបស់យើង (របស់បារាំង) ព្រះអង្គទ្រង់បានលៃធ្វើយ៉ាងណាកុំអោយសង្គ្រាមនេះ

ផ្តល់គ្រោះថ្នាក់ដល់ព្រះអង្គគឺធ្វើយ៉ាងណាអោយមានលក្ខណៈជាការបះបោររបស់ប្រជារាស្ត្រទៅវិញ ហើយដែលគេមិនអាចដាក់កំហុសទៅលើព្រះអង្គបាន ។ កិច្ចការដ៏លំបាកនោះ ព្រះអង្គទ្រង់បានបំពេញដោយការប៉ិនប្រសប់ជាទីបំផុត ។ ព្រះអង្គទ្រង់បានដឹកនាំការធ្វើសង្គ្រាមដោយគេមិនអាចចាប់ភស្តុតាងបានដោយជាក់ស្តែងម្តងណាឡើយ ។ផ្ទុយទៅវិញ ដរាបណាសង្គ្រាមនៅតែបន្តវែងឆ្ងាយទៅទៀត ដរាបនោះព្រះអង្គកាន់តែមិនត្រូវបាត់បង់កិត្តិយស ។ ដូចដែលព្រះអង្គទ្រង់សព្វព្រះទ័យប្រជារាស្ត្រដែលបានបញ្ចុះបញ្ចូលដោយពួកមេដឹកនាំបានធ្វើអោយសង្គ្រាមនោះមានលក្ខណៈជាការតស៊ូរបស់ជាតិទាំងមូល" ( Avant tout il allumera la guerre: car il ne désespère pas. Toutefois, affolé par le texte de la Convention qui lui révèle l'énergie de notre attitude, il s'arrangera de telle sorte que cette guerre soit pour lui sans péril, qu'elle ait l'apparence d'une insurrection, d'un soulèvement populaire et qu'il soit impossible de l'en rendre responsable. Cette entreprise si difficile à conduire, il la mène à bien avec une rare habilité, admirablement servi par ce tempérament asiatique qui déroute souvent les plus adroits. Il dirige la campagne sans qu'on puisse jamais le prendre en flagrant délit. Au contraire, plus les hostilités, se prolongent, moins il risque de se compromettre. Ainsi qu'il l'a voulu le peuple, travaillé et endoctriné par ceux pui entretiennent le mouvement, donne à cette guerre toute la physionomie d'une révolte nationale)(50).

ចំពោះរឿងដដែលនេះ ជនជាតិបារាំងម្នាក់ទៀតគឺលោក André Migot បានសរសេរថា : "មិនដល់មួយឆ្នាំក្រោយពីការចុះហត្ថលេខាលើសន្ធិសញ្ញា ១៨៨៤ មានការបះបោរយ៉ាងខ្លាំងក្លាបានផ្ទុះឡើងដើម្បីប្រឆាំងនឹងខសំខាន់នៃសន្ធិសញ្ញានោះ ។ គេច្រើនតែចាត់ទុកថា ការបះបោរដែលបណ្តាលអោយមានការបង្ហូរឈាមនៅប្រទេសកម្ពុជា ជាស្នាដៃរបស់ពួកស្តេច ឬពួកអ្នកផ្សងព្រេងល្មោភអំណាច ឬរបស់ពួកឧទ្ទាមដែលមានចិត្តថ្លើមជាចោរទៅវិញ ។ តាមការពិត នេះគឺជាការបះបោររបស់អ្នកស្នេហាជាតិខ្មែរក្នុងគោលបំណងរំដោះប្រទេសជាតិរបស់ខ្លួនអោយរួចពីនឹមបរទេស ឬក៏ជាការតស៊ូរបៀបចំបាំងឈ្លបដែលមានការរៀបចំយ៉ាងទូលំទូលាយហើយដែលមានការគាំទ្រពីសំណាក់ពួកស្តេចនិងព្រះសង្ឃ ។ ពិតមែនហើយថានៅគ្រាដំបូងពុំមានទំនាក់ទំនងជិតស្និទ្ធរវាងរាជវង្សានុវង្ស និងប្រជារាស្ត្រជាអ្នកប្រយុទ្ធ ប៉ុន្តែគេដឹងច្បាស់ថា ព្រះបាទ**នរោត្តម** ទ្រង់បានខិតខំគាំទ្រនូវចលនាតស៊ូ ហើយជនជាតិបារាំងក៏តែងតែជឿថា គឺព្រះអង្គនេះហើយជាអ្នកមេគំនិត ។ ទោះបីការបះបោរត្រូវទទួលបរាជ័យក៏ដោយ ក៏ការបះបោរនោះបានពង្រឹងជំហររបស់ព្រះរាជាដែលអាចទាមទារយកពីជនជាតិបារាំងនូវសម្បទានខ្លះ " (Moins d'un an après la signature du traité de 1884, de graves soulèvements avaient éclaté pour protester contre les termes du traité. On a souvent présenté les révoltes qui ensanglantèrent le Cambodge comme le fait de princes ou d'aventuriers avides, du pouvoir, de "rebelles " plus ou moins

assimilés à des bandits, En réalité il s'agissait d'un soulèvement de patriotés cambodgiens ayant pour but la libération de leur pays du joug de l'étranger, d'une lutte de guérillas organisée sur une vaste échelle, soutenue par des princes ou des bonzes bouddhistes. Bien qu'il n'y ait pas eu au début de contact direct entre la famille royale et le peuple combattant, il est bien évident que le roi Nobodom faisait ce qu'il pouvait pour soutenir le mouvement et les Français restèrent toujours persuadés qu'il en était l'instigateur. Si l'insurrection fut vaincue, elle n'en réussit pas moins à épaule le roi qui, grâce à elle, réussit à arracher aux Français un certain nombre de concessions)(50).

ការតស៊ូរបស់អ្នកស្នេហាជាតិខ្មែរមានរយៈពេលម្ភៃប្រាំមួយខែ (ពីខែវិច្ឆិកា ១៨៨៤ ដល់ ខែមករា ១៨៨៧) ហើយបានប្រព្រឹត្តទៅទូទាំងប្រទេស ។ បារាំងត្រូវលើកទ័ពទៅតស៊ូ និងអ្នកស្នេហាជាតិនៅគ្រប់ទិសទី ។ នៅក្នុងទីក្រុងដែលមានទាហានការពារយ៉ាងមាំទាំ គេឃើញមានការធ្វើឃាតយ៉ាងច្រើន ជាហេតុនាំអោយទាហានធ្លាក់ទឹកចិត្តយ៉ាងខ្លាំង ។ ទ័ពបារាំងត្រូវទទួលការខូចខាតយ៉ាងដំណំព្រោះត្រូវទប់ទល់នឹងការវាយប្រហាររបស់អ្នកស្នេហាជាតិខ្មែរផង ត្រូវស្លាប់ដោយជម្ងឺ និងធាតុអាកាសផង ។

ក្រោយពីលោក Jules Ferry ចេញចាកពីឆាកនយោបាយទៅ រដ្ឋាភិបាលបារាំងបានស្គាល់នូវការភ័ន្តច្រឡំរបស់ខ្លួន ដោយសារការផ្តល់ពត៌មានពីលោក Piquet ជារេស៊ីដង់ស៊ុប៉េរីយ័រ ។ បារាំងបានប្រគល់អំណាចទៅអោយព្រះរាជាវិញ ទុកអោយមានតែរេស៊ីដង់ស៊ុប៉េរីយ័រម្នាក់នៅអមព្រះអង្គ ។ កិច្ចការរដ្ឋត្រូវបានប្រគល់ទៅអោយមន្ត្រីខ្មែរកាន់កាប់វិញ ។ នៅតាមខេត្ត នៅមានតែរេស៊ីដង់បារាំង ៤ នាក់ប៉ុណ្ណោះ (នៅកំពត ក្រចេះ កំពង់ធំ និងពោធិ៍សាត់) ដែលបានទទួលបញ្ជាថាមិនត្រូវទៅជ្រៀតជ្រែកក្នុងកិច្ចការរបស់អ្នកស្រុក ហើយត្រូវគោរពទំនៀមទំលាប់ប្រពៃណី និងសាសនារបស់អ្នកស្រុកថែមទៀត ។ ការកែទំរង់ទាំងឡាយដែលលោករេស៊ីដង់ស៊ុប៉េរីយ័របានស្នើត្រូវបានទទួលសេចក្តីយល់ព្រមពីព្រះមហាក្សត្រិយ៍សិនទើបអាចយកទៅអនុវត្តបាន ។

លុះព្រះរាជាយល់ព្រមតាមនយោបាយថ្មីរបស់បារាំងនៅប្រទេសខ្មែរហើយ សន្តិភាពក៏មានឡើងវិញ ដោយព្រះអង្គទ្រង់បានយាងទៅជួបពួកមេដឹកនាំការតស៊ូទាំងអស់នៅវត្ត **ព្រៃនគរ** ហើយទ្រង់បានបញ្ជាក់ប្រាប់ថារដ្ឋការបារាំងបានប្រគល់អំណាចមកអោយខ្មែរវិញ ។ ដូច្នេះ ការតស៊ូរបស់អ្នកស្នេហាជាតិក៏ត្រូវបញ្ចប់ត្រឹមពេលនោះដែរ ។ គួរគប្បីជ្រាបថា ពួកមេដឹកនាំសំខាន់ៗ នៅពេលនោះមានជាអាទិ :

- **ខុកញ៉ាខុនធំយាធិរាជ** ចៅហ្វាយស្រុកសំរោងទង
- **ខុកញ៉ាខត្យាខុនធំយនិត** ចៅហ្វាយស្រុកភ្នំស្រួច
- **វិបុលរាជកែប** នៅគងពិសី
- **ខត្យាអគ្គរាជញ៉ឹក** នៅកណ្តាលស្ទឹង
- **វិបុលសង្គ្រាមស** នៅស្អាង
- **ចក្រីម៉ា** នៅបាទី

ចំណែកឯ **ក្រឡាហោមគង់** និង **ពិស្ណុលោកឈូក** មិនបានអញ្ជើញទៅជួបជុំក្នុងពេលនោះទេ លោកគ្រាន់តែបានចាត់តំណាងអោយទៅទូលសុំធ្វើសវនាការជាមួយព្រះរាជានៅថ្ងៃក្រោយ ។ គេដឹងថា លុះស្រុកបានសន្តិភាពហើយ លោក **ពិស្ណុលោកឈូក** ត្រូវគេលួចធ្វើឃាត ឯលោក **ក្រឡាហោមគង់** ត្រូវបារាំងអោយនាម៉ឺនខ្មែរម្នាក់បញ្ឆោតអោយឡើងមើលកប៉ាល់វា ហើយត្រូវចាប់ចងផ្តោបនឹងបំពង់ភ្លើងកប៉ាល់ រហូតដល់ក្សិណក្ស័យជីវិតទៅ (54) ។

## ៨. បញ្ហាដែនដីកូសាំងស៊ីន និងបញ្ហាព្រំដែន

នៅគ.ស. ១៨៦៤ ព្រះបាទ **នរោត្តម** ដោយមានលោក Doudart de Lagrée **អមផង** បានយាងទៅជួបលោកទេសាភិបាល de la Grandière នៅក្នុងព្រៃនគរ ហើយបានធ្វើសំណូមពរចំពោះលោកទេសាភិបាលសូមអោយប្រទេសបារាំងបង្វិលសងមកខ្មែរវិញនូវខេត្តទាំងអស់គឺ **លង់ហោរ** (លង់ហោរ ព្រះត្រពាំង ផ្សារដែក) **មាត់ជ្រូក** (មាត់ជ្រូក បារាជ ព្រែកឫស្សី ឃ្លាំង ) និង**ពាម** (ពាម ក្រមួនស ពលលាវ) ដែលស្ថិតនៅក្នុងការកាន់កាប់របស់យួននៅឡើយតាមសន្ធិសញ្ញា១៨៦២ ។ ព្រះអង្គទ្រង់បានទទួលពាក្យសន្យាពីរឿងនេះ ហើយក៏យាងត្រឡប់ចូលរាជធានី **ឧដុង្គ**វិញ ដោយទ្រង់មានសង្ឃឹមថាទឹកដីដែលបាត់បង់នោះនឹងត្រូវបានបញ្ចូលជាទឹកដីខ្មែរដូចដើមវិញមិនខាន ។ ក៏ប៉ុន្តែ នៅគ.ស.១៨៦៧ ដោយហេតុថាខេត្តទាំង៣នោះជាកន្លែងដែលយួនធ្វើសកម្មភាពប្រឆាំងបារាំង លោកទេសាភិបាលកូសាំងស៊ីនក៏វាយយកបញ្ចូលជាអាណានិគមរបស់លោកតរៀងទៅ ដោយភ្លេចនឹកដល់ពាក្យសន្យារបស់លោកចំពោះព្រះបាទ **នរោត្តម** (55) ។

ដូច្នេះ ចាប់តាំងពីគ.ស. ១៨៦៧ ទឹកដីកម្ពុជាក្រោមទាំងមូលបានក្លាយទៅជាអាណានិគមរបស់បារាំង ។ ចំណែកឯកម្ពុជាលើមានលក្ខន្តិកៈជាប្រទេសអាណាព្យាបាល ។ ម្ល៉ោះហើយ អាជ្ញាធរបារាំងនៅកូសាំងស៊ីនតែងតែធ្វើការកែប្រែបន្ទាត់ព្រំដែនតាមទំនើងចិត្តខ្លួនរវាងប្រទេសទាំងពីរ ដែលមានរបបខុសគ្នាដោយសំអាងលើហេតុផលខាងរដ្ឋបាល ឬខាងសេដ្ឋកិច្ច ។ គេបានសង្កេតឃើញថា ការកែប្រែ

ទាំងនោះសុទ្ធតែធ្វើអោយចំណេញទឹកដីទៅខាងកូសាំងស៊ីនជានិច្ច ដោយមិនអើពើដល់ការតវ៉ារបស់ព្រះរាជាខ្មែរ ឬដោយមិនស្នើសួរព្រះយោបល់ផងទេ (56) ។

ចាប់ពីឆ្នាំ ១៨៩៣ដល់ឆ្នាំ ១៩១៤ ប្រទេសខ្មែរត្រូវបាត់បង់ទឹកដីថែមមួយភាគទៀត ដោយហេតុតែបារាំងបានប្រវិញយកទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីន ឬក្នុងប្រទេសអាណ្ណាមទៅវិញ (57) ។

នៅគ.ស. ១៨៩៨ លោករេស៊ីដង់ស៊ុបេរីយ័រ នៃប្រទេសលាវបានដកហូតយកពីខេត្តស្ទឹងត្រែងនូវដី ១ដុំ ដើម្បីបង្កើតជាស្ថងការដ្ឋាន Darlac ដែលក្រោយមកត្រូវគេយកទៅបញ្ចូលក្នុងប្រទេសអាណ្ណាម នៅគ.ស.១៩២៩ ។ នៅគ.ស. ១៨៩៣ អនុក្រិត្យ (arrêté) របស់លោកទេសាភិបាលកូសាំងស៊ីនបានបញ្ចូលស្រុកខ្មែរពីរ គឺ **គីវអាញ់** (Cuu Anh) និង **ថាញ់ អាញ** (Than Anh) នៅឯនាយ **ឡុកនិញ** (Loc Ninh) និងស្រុកស្មៀងពីរគឺ **ឡុតនិញ** និង **ភឿកឡេ** (phuoc Lê) ទៅក្នុងវៀង (ស្រុក) **កាន់ឡេ** (Can Lê) ក្នុងបំណងដើម្បីកែនមនុស្សទៅស្ថាបនាផ្លូវពី **ចៀនថា** ទៅ **ក្រចេះ** ។ ដែនទីដែលបោះពុម្ពមុនឆ្នាំ១៩០៣ សុទ្ធតែដាក់ថាស្រុក **ឡុកនិញ** និង **ភឿកឡេ** ជាទឹកដីខ្មែរទាំងអស់ ។

លុះដល់ឆ្នាំ ១៩១៤ ទើបមានអនុក្រិត្យមួយរបស់លោកអគ្គទេសាភិបាលចំរេចបញ្ចូលស្រុកពីរនោះក្នុងដែនដីកូសាំងស៊ីន ។

ខាងផ្នែក **ពេទជីរ៍** លិខិតផ្លូវការជាច្រើនបានបញ្ជាក់ពីការដកហូតយកដីខ្មែរទៅបញ្ចូលក្នុងដែនកូសាំងស៊ីន គឺស្រុក **ខេីចធាដែខ ចឹខថ្នំ ស្រុកត្រាញ់** និងដីស្ថិតនៅត្រង់ចន្លោះនៃទន្លេ **វាយគោ** (Vaico) ទាំងពីរ ។

ខាងផ្នែក **ពាម** បារាំងបានយកឃុំពីរគឺ **កោះចន្ទុះ** និង **សាគី** នៅគ.ស. ១៨៩៣ ដើម្បីយកទៅបញ្ចូលក្នុងដែនកូសាំងស៊ីនទៀត ។ មានអនុក្រិត្យមួយរបស់លោកអគ្គទេសាភិបាលធ្វើនៅឆ្នាំ ១៩១៤ បានបញ្ជាក់ពីរឿងនេះ ។

ចំពោះកោះទាំងឡាយវិញ អាជ្ញាធរបារាំងនៅកូសាំងស៊ីនក៏ដូចជាអាជ្ញាធរបារាំងនៅប្រទេសកម្ពុជាសុទ្ធតែបានទាមទារទុកជាកម្មសិទ្ធិតែរៀងខ្លួន ។ តាមផ្លូវច្បាប់ គេឃើញមានសារាចរមួយរបស់លោកអគ្គទេសាភិបាល Brévié ចុះថ្ងៃទី៣១ ខែមករា ១៩៣៩ ដែលបានថែងថា " កោះទាំងឡាយដែលស្ថិតនៅខាងជើងបន្ទាត់មួយកែងនឹងឆ្នេរសមុទ្រ ត្រង់ចំណុចព្រំដែនរវាងប្រទេសកម្ពុជា និងកូសាំងស៊ីននឹងត្រូវគ្រប់គ្រងដោយប្រទេសកម្ពុជា ។ អាជ្ញាធរអាណាព្យាបាលនឹងរាប់រងជាពិសេសនូវបញ្ហាប៉ូលីសលើកោះទាំងនោះ ។

ចំណែកឯកោះទាំងឡាយដែលស្ថិតនៅខាងត្បូងបន្ទាត់នោះ : គិតទាំង **កោះត្រល់** ទាំងមូលផងនឹងត្រូវគ្រប់គ្រងដោយអាជ្ញាធរដែនកូសាំងស៊ីន " (56) ។

ដូច្នេះ យើងឃើញថា ព្រំដែនរវាងប្រទេសកម្ពុជា និងដែនដីកូសាំងស៊ីនមានលក្ខណៈជាព្រំដែនរដ្ឋបាលច្រើនជាងព្រំដែននយោបាយ ។ ខ្មែរត្រូវបាត់បង់ទឹកដីទទេៗព្រមទាំងកោះខ្លះមាន **កោះត្រល់** ជាដើម មកតែពីចិត្តលោភលន់របស់បារាំងតែប៉ុណ្ណោះ ។

ចាប់តាំងពីគ.ស. ១៨៨៧ តទៅ ប្រទេសខ្មែរបានស្ថិតនៅក្នុងសន្តិភាព ប៉ុន្តែទឹកដីត្រូវបារាំងខ្វេះម្តងម្តុំៗ យកទៅបញ្ចូលឯណេះ ឬ ឯណោះតាមតែអំពើចិត្តរបស់ខ្លួន ។

ព្រះបាទ **នរោត្តម** ទ្រង់បានសោយទិវង្គត នៅថ្ងៃទី២៤ ខែ មេសា ១៩០៤ ដោយរោគថ្កាម នៅវេលាម៉ោង៣ល្ងាច ។ ព្រះអង្គទ្រង់មានមរណនាមថា **សុវណ្ណកោដ្ឋ** ។

## ខ. បារាំងបានធ្វើអ្វីខ្លះជាប្រយោជន៍ដល់ខ្មែរ ?

### ១. ព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧)

នាថ្ងៃ២៤ មេសា ដដែលនោះ វេលាម៉ោង៣និង២០នាទីល្ងាច **ក្រុមប្រឹក្សារាជបល្ល័ង្ក** (Conseil de la Couronne) ដែលមានគណៈរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ទាំងបព្វជិត និងទាំងគ្រហស្ថបានបើកសម័យប្រជុំក្រោមអធិបតីភាពនៃលោក រេស៊ីដង់ស៊ុបេរីយ័រ ដើម្បីជ្រើសរើសព្រះមហាក្សត្រិយ៍ថ្មីទៅតាមប្រពៃណីខ្មែរ ។ ដោយហេតុថាព្រះបាទ **នរោត្តម** ពុំសូវស្និទ្ធស្នាលនឹងបារាំង ព្រះរាជបុត្ររបស់ព្រះអង្គពុំត្រូវបានជ្រើសរើសអោយឡើងសោយរាជ្យស្នងព្រះបិតាទេ ។ ពេលនោះ **ក្រុមប្រឹក្សារាជបល្ល័ង្ក** ដែលមានលោក រេស៊ីដង់ស៊ុបេរីយ័រ ជាអធិបតីនោះ បានសំរេចជ្រើសរើសព្រះមហាឧបរាជ **ស៊ីសុវត្ថិ** ជាព្រះអនុជព្រះបាទ **នរោត្តម** អោយឡើងសោយរាជ្យវិញ (58) ។

បើតាមលោក Paul Collard ព្រះបាទ **ស៊ីសុវត្ថិ** ជាបុគ្គលដែលគួរអោយស្រឡាញ់ជាទីបំផុត ជាមនុស្សដែលមានចិត្តទូលាយ និងចិត្តមេត្តាជាទីបំផុតក្នុងចំណោមខ្មែរទាំងឡាយ (58) ។ ព្រះអង្គទ្រង់បានខិតខំទាំងកម្លាំងព្រះទ័យ និងទាំងកម្លាំងព្រះកាយ ដើម្បីធ្វើអោយមានសន្តិភាព និងធ្វើអោយប្រជារាស្ត្របានសម្បូណ៌សប្បាយ ។

លុះបានឡើងសោយរាជ្យភ្លាម ព្រះអង្គទ្រង់បានប្រកាសអោយប្រើនូវព្រះរាជបញ្ញត្តិថ្ងៃទី២១ ខែ ឧសភា ១៩០៤ ដែលបញ្ជាអោយលប់ចោលនូវការធ្វើទុក្ខបុកម្នេញលើរាងកាយនៃជនមានទោស និងលើជនដែលត្រូវជាប់ចោទ ។

នៅឆ្នាំក្រោយ ព្រះអង្គទ្រង់បានបញ្ញត្តិអោយលប់ចោលនូវ **កំណាន់ខេត្ត** និងបញ្ញត្តិថា អំណើះតទៅកិច្ចការរដ្ឋបាលទាំងឡាយនៃព្រះរាជាណាចក្រត្រូវសិក្សាពិនិត្យដោយលោក **អគ្គមហាសេនា** (រដ្ឋ

មន្ត្រីទី ១) រួចទៅត្រូវយកទៅដាក់ជូនលោករេស៊ីដង់ស៊ុប៉េរីយ័រពិនិត្យទៀត (រាជបញ្ញត្តិថ្ងៃ ទី ៥ ខែ ឧសភាព ១៩០៥)។ គួរគប្បីជ្រាបថា នៅមុននេះទឹកដីប្រទេសកម្ពុជាទាំងមូលត្រូវបែងចែកជាមណ្ឌលរដ្ឋបាលធំៗប្រាំ តាមចំនួនរដ្ឋមន្ត្រីទាំងប្រាំដែលត្រូវគ្រប់គ្រងមណ្ឌលនិមួយៗ ហើយដែលមានងារជា **កំណាន់ខេត្ត**។ ចាប់តាំងពីពេលនោះទៅ ពួកចៅហ្វាយខេត្តមិនឡើងទៅរដ្ឋមន្ត្រីណាមួយទៀតទេ តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់រដ្ឋបាលអាណាព្យាបាលបារាំង។ នៅឆ្នាំដដែលនោះ តាមព្រះរាជបញ្ញត្តិថ្ងៃទី៣ ខែកក្កដា ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានបញ្ជាក់ពីមុខងាររបស់រដ្ឋមន្ត្រីទាំង៥មានដូចតទៅ :

- **ឧកញ៉ាអគ្គមហាសេនា** : មានមុខងារជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ និងជាអធិបតីនៃគណៈរដ្ឋមន្ត្រី។

- **ឧកញ៉ាយមរាជ** : មានមុខងារជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

- **ឧកញ៉ាវាំង** : មានមុខងារជារដ្ឋមន្ត្រីទទួលខុសត្រូវកិច្ចការក្នុងរាជវាំង ខាងហិរញ្ញវត្ថុ និងខាងវិចិត្រសិល្បៈ។

- **ឧកញ៉ាក្រឡាហោម** : មានមុខងារជារដ្ឋមន្ត្រីទ័ពជើងទឹក ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្ម។

- **ឧកញ៉ាចក្រី** : មានមុខងារជារដ្ឋមន្ត្រីខាងសង្គ្រាម សាធារណការ និងការសិក្សាសាធារណៈ។

ចំពោះទឹកដីដែលត្រូវបាត់បង់ទៅក្នុងដៃសៀមនោះ គេដឹងថាក្នុងឆ្នាំ១៩០៤ ប៉ុន្មានខែក្រោយដែលព្រះបាទ **ស៊ីសុវត្ថិ** បានឡើងសោយរាជ្យ ប្រទេសសៀមបានបង្វិលទៅអោយបារាំង ហើយដែលបារាំងបានប្រគល់អោយព្រះអង្គវិញនូវខេត្ត**ត្រាច** (ត្រាត ?) **កោះកុង** ? (Ko-Kong) **ម្លូព្រៃ** និង **ទន្លេរពៅ**។ នៅពេលជាមួយគ្នានោះ ខេត្ត **ស្ទឹងត្រែង** និងស្រុក **សៀមប៉ាង** ក៏ត្រូវដកហូតពីប្រទេសលាវហើយប្រគល់មកអោយព្រះរាជាខ្មែរវិញដែរ (10)។

តាមសន្ធិសញ្ញាថ្ងៃទី ២៣ ខែមីនា ១៩០៧ រដ្ឋាភិបាលសៀមបានប្រគល់អោយបារាំងវិញនូវខេត្ត **បាត់ដំបង សៀមរាប** និង **ស៊ីសុផុន**។ ប៉ុន្តែបារាំងត្រូវអោយជាថ្នូរទៅវិញនូវដែនដី **ដាន់ សៃ** (Dan-Sai) និង**ត្រាច** (ត្រាត?)។ ខេត្តទាំង៣ខាងលើ បារាំងបានប្រគល់អោយមកខ្មែរវិញ។

គួរគប្បីជ្រាបថា ការវិលចូលមកក្នុងមាតុភូមិវិញនូវទឹកដីមួយភាគយ៉ាងសំខាន់ដែលត្រូវបាត់បង់ទៅតាំងពីសម័យពញាអភ័យធិបែស **បែន**(១៧៩៥) ជាជោគជ័យមួយនៃនយោបាយបារាំងនៅប្រទេសកម្ពុជា ដែលមានចារឹកទុកជាអនុស្សាវរីយ៍នៅត្រង់ទិសខាងត្បូងវត្តភ្នំជូនពេញសព្វថ្ងៃ។ ការទាមទារយកបានទឹកដីនេះមកវិញ គឺធ្វើឡើងក្នុងពេលដែលលោក Armand Fallières កាន់តំណែងជាប្រធានា

ធិបតីនៃសាធារណរដ្ឋបារាំង លោក Paul Beau ជាអគ្គទេសាភិបាលនៃឥណ្ឌូចិន និងលោក Paul Luce ជារេស៊ីដង់ស៊ុបេរីយ័រ នៅប្រទេសកម្ពុជា ។

នាឆ្នាំ ១៩០៧ ដដែលនោះ មានបង្កើតគណៈកម្មការពីរសំរាប់ចងក្រងរាជពង្សាវតារខ្មែរ ៖ គណៈកម្មការទី១ មាន**លោកឧកញ៉ា វាំងជួន** ជាប្រធាន គណៈកម្មការទី២ មានលោកឧកញ៉ាវង្សា **អគ្គរាជ នុច** ជាប្រធាន ។

តាមរាជបញ្ញត្តិថ្ងៃទី ១១ ខែមេសា ១៩១២ ឪពុកម្តាយត្រូវតែបញ្ជូនកូនប្រុសស្រីអោយទៅកាន់សាលារៀន បើពុំដូច្នោះទេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងទម្ងន់ ។ សូមជ្រាបថានៅសម័យនោះ ក្រៅពីសាលាវត្តរាជការបានបង្កើតសាលានៅតាមឃុំជាច្រើនទៀត ដើម្បីអោយក្មេងសិក្សាភាសាជាតិខ្លួន ។ ចំពោះក្មេងណាដែលចង់បន្តការសិក្សាថែមទៀត រដ្ឋការអាណាព្យាបាលបារាំងបានបង្កើតសាលាបឋមសិក្សាជាន់ដំបូងខ្លះដែលនៅទីនោះ គេមានផ្តើមការបង្រៀនភាសាបារាំង ។ នៅពីលើសាលាទាំងនោះនៅមានសាលាដែលមានកំរិតវិជ្ជាខ្ពស់ជាងនៅតាមទីរួមខេត្ត ហើយដែលមានចាងហ្វាងជាបារាំង ។

សំរាប់មធ្យមសិក្សា គេមានតែអនុវិទ្យាល័យស៊ីសុវត្ថិមួយគត់នៅរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩០៤ម្ល៉េះ ។

ក្នុងវិស័យសិក្សាអប់រំ និងវប្បធម៌នេះ គេបានដឹងថាតាមរាជបញ្ញត្តិថ្ងៃទី៤ ខែកញ្ញា ១៩១៥ ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានបង្កើតគណៈកម្មការមួយដែលមាននាទីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង រួចនៅគ.ស.១៩២១ ព្រះអង្គទ្រង់បានសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ ។ម្យ៉ាងទៀត នៅក្នុងរជ្ជកាលរបស់ព្រះអង្គដដែល (១៩១៨) លោក Georges Groslier បានបង្កើតសារមន្ទីរមួយនៅក្រុងភ្នំពេញ ដើម្បីប្រមែប្រមូលនូវស្នាដៃខ្មែរដែលជាវត្ថុបុរាណយកមកថែរក្សាអោយបានគង់វង់តទៅ ។

គួរកត់សំគាល់ដែរថា ចាប់តាំងពីឆ្នាំ ១៩១២ ព្រះរាជាទ្រង់បានប្រកាសអោយប្រើនូវក្រមព្រហ្មទណ្ឌថ្មី ។ នៅឆ្នាំបន្ទាប់ ក្រុមស៊ើបអង្កេតបទឧក្រិដ្ឋ និងនៅឆ្នាំ១៩២០ ក្រុមរដ្ឋប្បវេណី និងក្រមនីតិវិធីខាងបទបវេណី ក៏ត្រូវបានប្រកាសអោយប្រើជាបន្តបន្ទាប់គ្នា ។ ក្រោយមកទៀតរាជបញ្ញត្តិថ្ងៃទី ១៤ ខែកញ្ញា ១៩២២ បានបង្កើតអោយមានសាលាលហុ សាលាដំបូង សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ។ ប៉ុន្តែសាលាទាំងនោះ ឬវិស័យតុលាការទាំងមូលត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់រដ្ឋការអាណាព្យាបាលបារាំង ។

ក្នុងវិស័យហិរញ្ញវត្ថុ គួរគប្បីរំលឹកឡើងវិញថាចាប់តាំងពីឆ្នាំ ១៨៩០ មកបញ្ជីចំណូលចំណាយនៃប្រទេសកម្ពុជាត្រូវកាន់កាប់ដោយហិរញ្ញិកម្នាក់ ។ ម្យ៉ាងទៀត នៅរៀងរាល់ឆ្នាំ លោករេស៊ីដង់ស៊ុបេរីយ័រត្រូវរៀបចំថវិកាសំរាប់ឆ្នាំខាងមុខ ។ ចាប់ពីឆ្នាំ១៩១២ គេបានគ្រោងក្នុងផ្នែកចំណាយនូវមុខចំណាយដូចតទៅ ៖

- មុខចំណាយសំរាប់រដ្ឋបាលទាំងខាងខ្មែរទាំងខាងបារាំង

- មុខចំណាយសំរាប់សន្តិសុខសាធារណៈ និងតុលាការ

- មុខចំណាយសំរាប់ហិរញ្ញវត្ថុ និងធនធានសាធារណៈ

- មុខចំណាយសំរាប់គិលានសង្គ្រោះ និងសិក្សាធិការ

ហើយដើម្បីទប់ទល់នឹងមុខចំណាយទាំងប៉ុន្មានខាងលើនេះ គេបានបង្កើតនូវប្រភេទពន្ធផ្សេងៗមាន :

- ពន្ធលើខ្លួន

- ពន្ធលើការអោយខ្ចី

- ពន្ធលើដីធ្លី និងដំណាំ

- ពន្ធប៉ាតង់

- ពន្ធលើផលិតផលព្រៃឈើ លើផលិតផលដាក់ភាសី លើផលិតផលអាជីវកម្មឧស្សាហកម្ម និងផលិតផលផ្សេងៗ (10) ។

ក្នុងវិស័យសេដ្ឋកិច្ច គេបានដឹងថាក្នុងរជ្ជកាលរបស់ព្រះបាទ **ស៊ីសុវត្ថិ** ចំការកៅស៊ូត្រូវបានបង្កើតជាលើកដំបូងនៅត្រង់តំបន់ **ជប់**(១៩២១) ។ ដោយការសាកល្បងនេះមានជោគជ័យ ពួកមូលធននិយមបារាំងបានបង្កើតចំការកៅស៊ូធំៗផ្សេងទៀតនៅត្រង់តំបន់ដីក្រហមក្នុងខេត្តកំពង់ចាម និងក្រចេះ ។ ដប់ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៣១ ទំហំផ្ទៃដីដាំកៅស៊ូឡើងហួសពី ២៥០០០ហិចតា (59) ។

នៅទីបញ្ចប់នេះ គួរកត់សំគាល់ថាក្នុងរជ្ជកាលរបស់ព្រះបាទ **ស៊ីសុវត្ថិ** រាស្ត្រខ្មែរបានក្រោកឡើងប្រឆាំងនឹងការរំលោភជិះជាន់របស់បារាំងអស់ពីរលើក ។ យ៉ាងណាមិញ នៅឆ្នាំ១៩១៦ ដើម្បីជាការដឹងគុណចំពោះរដ្ឋការបារាំង ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានអនុញ្ញាតអោយពួកនេះកែនរាស្ត្រខ្មែរធ្វើទាហានយកទៅច្បាំងនៅប្រទេសបារាំង សង្គ្រាមសកលលោកលើកទី១ (១៩១៤-១៩១៨) ។ ប៉ុន្តែមិនយូរប៉ុន្មានរាស្ត្រខ្មែរចំនួនមួយសែននាក់បានបះឡើងប្រឆាំងនឹងការរំលោភក្នុងកំណែនខាងលើនេះ និងក្នុងការស្លាបនាផ្លូវថ្នល់ ។ ជាកុសល ព្រះរាជាទ្រង់បានធ្វើអន្តរាគមន៍យ៉ាងសក្តិសិទ្ធិ ប្រជារាស្ត្ររបស់ព្រះអង្គក៏សុខចិត្តព្រមវិលទៅលំនៅដ្ឋានរៀងៗខ្លួនវិញទៅ ។

ក្រោយមក ប្រហែលជាដោយសារបារាំងត្រូវការលុយកាក់នាំយកទៅស្រុករបស់ខ្លួន ដែលបានងើបពីចម្បាំងជាមួយពួកអាល្លឺម៉ង់ បារាំងក៏បានតម្លើងពន្ធដា ហើយតឹងទារពីរាស្ត្រខ្មែរដែលមានជីវភាពកាន់តែយ៉ាប់យ៉ឺនទៅៗ ។ ម្ល៉ោះហើយ រាស្ត្រខ្មែរដែលនៅកន្លែងខ្លះអត់ទ្រាំនឹងអំពើជិះជាន់នេះមិនបានក៏នាំគ្នាបះឡើងរហូតដល់ហ៊ានសម្លាប់រេស៊ីដង់បារាំង ដូចករណីលោករេស៊ីដង់ Bardez នៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ១៨ ខែមេសា ១៩២៥ (60) ។

## ២. ព្រះបាទស៊ីសុវត្ថិមុនីវង្ស (១៩២៧-១៩៤១)

ព្រះបាទ **ស៊ីសុវត្ថិ** បានសោយទិវង្គត នៅថ្ងៃ ៩ ខែ សីហា ១៩២៧ ក្នុងជន្មាយុ ៨៧ វស្សា ។ ក្រុមប្រឹក្សារាជបល្ល័ង្ក ដែលស្ថិតនៅក្រោមអធិបតីភាពនៃលោក Le Fol រេស៊ីដង់ស៊ុបេរីយ័រ បានជ្រើសរើសព្រះរាជបុត្រច្បងនាម **ស៊ីសុវត្ថិមុនីវង្ស** អោយឡើងសោយរាជ្យស្នងព្រះបិតា ។ ពិធីរាជាភិសេកបានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ(កក្កដា ១៩២៨) នៅចំពោះមុខលោក អគ្គទេសាភិបាលឥណ្ឌូចិន និងលោករេស៊ីដង់ស៊ុបេរីយ័រនៃប្រទេសខ្មែរ (10) ។



*ព្រះបាទស៊ីសុវត្ថិមុនីវង្ស ក្នុងថ្ងៃសោយរាជ្យ*
(រូបស្រង់ចេញពីសៀវភៅសិក្សាសង្គម ថ្នាក់ទី១១ ទំព័រ ២១៣ បោះពុម្ពឆ្នាំ២០០០)

ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានយាងទៅសិក្សាយោធវិជ្ជានៅប្រទេសបារាំង ព្រមទាំងបានក្លាយទៅជាមេទាហានមួយរូបនៃកងទ័ពប្រទេសនេះទៀតផង ។

ដូចយើងបានឃើញរួចមកហើយ នៅឆ្នាំ ១៩៣១ ទំហំផ្ទៃចំការកៅស៊ូនៅប្រទេសខ្មែរកាន់តែកើនឡើងជាលំដាប់ ។ ចំការកៅស៊ូនៅមេមត់ដែលមានផ្ទៃ៦ ០០០ហិចតានិងមានដើមកៅស៊ូ ៥៥០ ០០០ដើម ជាចំការធំបំផុតក្នុងពិភពលោកក្នុងសម័យនោះ ។ ដំណាំថ្នាំជក់ និងដំណាំពោតក៏ត្រូវបានគេផ្តើមធ្វើដែរ ។

ក្នុងវិស័យកសិកម្មដដែលនេះ ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានដាក់អោយបង្កើតផលឡើងវិញនូវដីស្រែធំទូលាយ ហើយដែលត្រូវជនជាតិខ្មែរបោះបង់ចោលដោយត្រូវភៀសខ្លួនគេចអោយផុតពីខ្មាំងឈ្លានពាន ឬ ដោយត្រូវចាប់យកទៅប្រទេសសៀមជាឈ្លើយ ។ ដូច្នេះ តំបន់ខ្លះដូចជា **ត្រពាំងជង** ជាដើម (ក្នុងខេត្តពោធិ៍សាត់) បានក្លាយទៅជាមណ្ឌលកសិកម្ម និងពាណិជ្ជកម្មមួយយ៉ាងសំខាន់ ។ នៅឆ្នាំ១៩៣០ ព្រះអង្គទ្រង់បានប្រកាសអោយប្រើនូវព្រះរាជបញ្ញត្តិ ដែលបង្កើតធនាគារសំរាប់ផ្តល់ឥណទានអោយកសិករនៅបាត់ដំបង ព្រៃវែង និងកំពង់ចាម (61) ។

ក្នុងវិស័យផ្លូវគមនាគមន៍ បណ្តាញផ្លូវថ្នល់ត្រូវបានគេពង្រីកយ៉ាងខ្លាំង ។ ផ្លូវរថភ្លើងទី១ពីភ្នំពេញទៅព្រំដែនសៀមដោយកាត់តាមបាត់ដំបង ត្រូវបានស្ថាបនាឡើងនៅគ.ស. ១៩៣២ ។ ផ្លូវនេះមានប្រវែង ២៧៥គ.ម. ។ ក្រៅពីនេះ ស្ពានធ្វើពីបេតុងជាច្រើនក៏ត្រូវបានស្ថាបនាដែរ ជាពិសេសស្ពាន

ដែលឆ្លងកាត់ទន្លេបាសាក់ (ប្រវែង ២៩២ម.) ហើយដែលមានឈ្មោះថា **ស្ពានព្រះមុនីវង្ស** ត្រូវបានសម្ពោធនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ១៩២៨ ។

ក្នុងវិស័យនយោបាយ និងវប្បធម៌ ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ក៏ទ្រង់បានសាងសមិទ្ធិយ៉ាងសំខាន់ៗណាស់ដែរដូចជា :

- **សភាសំរាប់អោយយោបល់** មួយ (សភាខ្មែរ)តាមរាជបញ្ញត្តិថ្ងៃទី ១៨ ខែសីហា ១៩២៨ ។ ប៉ុន្តែបើតាមលោក Henri Russier ថាសភានេះ (Assemblée consultative indigène) ត្រូវបានបង្កើតតាំងពីរជ្ជកាលមុនម្ល៉េះ ហើយត្រូវមានភារៈផ្តល់យោបល់ពីបញ្ហាពន្ធដា បញ្ហារដ្ឋបាល ឬបញ្ហាបង្កើតផលទាក់ទងនឹងជីវភាពប្រជារាស្ត្រខ្មែរ ។ សភានេះមានសមាជិក ៤៦ នាក់ : ក្នុងចំណោមនេះ៤១នាក់ត្រូវបោះឆ្នោតជ្រើសរើសដោយពួកបញ្ញវន្តខ្មែរ និង៥នាក់ទៀត ត្រូវបានតែងតាំងដោយគណៈរដ្ឋមន្ត្រី (10) ។

- **ក្រុមជំនុំប្រែព្រះត្រៃបិដក** ដែលត្រូវបានបង្កើតនៅថ្ងៃទី ១៤ ខែវិច្ឆិកា ១៩២៩ ហើយដែលមានភារៈបកប្រែព្រះ **ត្រៃបិដក** (វិន័យបិដក សុត្តន្តបិដក និង អភិធម្មបិដក) ។ សព្វថ្ងៃនេះគម្ពីរទាំង ៣ នេះត្រូវបានបកប្រែចប់សព្វគ្រប់ហើយ ហើយមានទាំងអស់ ១១០ក្បាល ។

- **វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ** ដែលត្រូវបានបង្កើតនៅឆ្នាំ ១៩៣០ ហើយដែលមានភារៈធ្វើការសិក្សាស្រាវជ្រាវពីព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជាតែម្តង មិនបាច់ចេញទៅបរទេសដូចមុនៗទៀត ។ ក្នុងឆ្នាំដដែល តាមរាជបញ្ញត្តិថ្ងៃទី ១៦ ធ្នូព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានរៀបចំនូវការសិក្សាភាសាបាលី និងព្រះពុទ្ធលទ្ធិក្នុងខេត្តទាំងឡាយនៃព្រះរាជអាណាចក្រ ។ ដោយហេតុនោះ មានការបង្កើត **សាលាអនុវត្តសំរាប់ព្រះសង្ឃ** ដែលនៅទីនោះព្រះសង្ឃ-គ្រូបានទៅសិក្សាពីវិធីបង្រៀនតាមបែបទំនើប ។

នៅឆ្នាំ ១៩៣៩ សង្គ្រាមសកលលោកលើកទី ២ បានផ្ទុះឡើង ។ ប្រទេសសៀមដែលមានវិវាទជាមួយប្រទេសបារាំង ត្រូវបានទទួលការគាំទ្រពីប្រទេសជប៉ុន ហើយនៅទីបំផុតបានកៀបសង្កត់ទៅលើប្រទេសបារាំងដណ្តើមយកទៅវិញនូវខេត្ត **បាត់ដំបង** និងទឹកដីស្ថិតនៅត្រង់ចន្លោះជួរភ្នំដងរែក និងខ្សែស្របក្រាដ (grade) ទី ១៥(61) ។

ដោយឈឺព្រះទ័យនឹងការរំលោភពីសំណាក់សៀមនេះ ព្រះសុខភាពត្រូវទ្រុឌទ្រោមយ៉ាងឆាប់រហ័ស ហើយព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់សោយទិវង្គតនៅរាត្រីទី ២២ ខែ មេសា ១៩៤១ នៅបូកគោក្នុងព្រះជន្មាយុ ៦៥ វស្សា ។

សរុបសេចក្តីមក ឃើញថាទោះបីបារាំងបានមកជិះជាន់ និងរំលោភលើប្រជារាស្ត្រខ្មែរខ្លះមែនរហូតដល់បានដកហូតទឹកដីប្រទេសកម្ពុជាយកទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីនរបស់ខ្លួន ហើយ

នៅទីបំផុតបានបញ្ចូលដោយមានសេចក្តីសំរេចពីរដ្ឋសភានូវដែនដីកូសាំងស៊ីនទៅក្នុងទឹកដីរបស់យួន ជំនាន់ព្រះចៅបៅដៃ (Bao Dai) នៅឆ្នាំ១៩៤៩ ជាហេតុធ្វើអោយខ្មែរក្រោមរាប់លាននាក់ត្រូវទទួលរង ទុក្ខវេទនាបាត់បង់សញ្ជាតិដើមរបស់ខ្លួនខ្លះមែនក៏ដោយ ក៏បារាំងមានឧបការគុណខ្លះៗដែរចំពោះប្រជា ជាតិខ្មែរយើង ។

យ៉ាងណាមិញ ពួកមន្ត្រី និងអ្នកប្រាជ្ញបារាំងបានធ្វើការរុករក និងសិក្សាស្រាវជ្រាវតាមបែប វិទ្យាសាស្ត្រ ហើយធ្វើអោយពិភពលោកបានស្គាល់នូវអតីតកាលរបស់ខ្មែរ ជាពិសេសពីសម័យមហា នគររុងរឿងដែលខ្មែរមានឋានៈជាមហាអំណាចមួយនៅតំបន់អាស៊ីអាគ្នេយ៍នេះ ។ ម្យ៉ាងទៀត អាណា ព្យាបាលភាពរបស់បារាំងទំនងជាបានការពារពូជពង្សខ្មែរ និងទឹកដីខ្មែរអោយបានគង់វង់រហូតមកដល់ សព្វថ្ងៃ គឺអោយចាកផុតពីការដណ្តើមគ្នាត្រួតត្រា និងលេបយកទឹកដីខ្មែរពីសំណាក់សៀមនិងយួនដែរ ។ ចំពោះរឿងនេះ មានជននៅជិតខាងខ្លះបានថ្លែងថា ប្រសិនបើបារាំងមកយឺតប្រហែលជា៥០ឆ្នាំប៉ុណ្ណោះ នោះប្រទេសកម្ពុជានឹងត្រូវរលាយជាមិនខាន ។ ក្នុងការកសាងជាតិ រដ្ឋការបារាំងក៏បានជួយធ្វើការកែ ទំរង់សំខាន់ៗ ខ្លះក្នុងវិស័យនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីអោយប្រទេសខ្មែរមានដំណើរជឿន លឿនទៅមុខ ក៏ប៉ុន្តែធម្មតាជាតិជាបរទេសបារាំងតែងបានប្រមែប្រមូលយកទ្រព្យសម្បត្តិខ្មែរ មាន សម្បត្តិវប្បធម៌ជាដើមទៅបំរើប្រយោជន៍ខ្លួនផ្ទាល់ ហើយពុំចង់អោយខ្មែរមានការចេះដឹង និងលូតលាស់ ខ្លាំងពេកទេ ព្រោះខ្លាចមានចលនាប្រឆាំងនឹងវត្តមានរបស់ខ្លួនតែប៉ុណ្ណោះ ។

## បញ្ជីស្តេចខ្មែរសោយរាជ្យពីគ.ស.១៧៥៨ ដល់ ១៩៤១

| លេខ<br>រជ្ជកាល | នាមសំរាប់រាជ្យ<br>នាមផ្ទាល់ | កាលកំនត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| 1 | នារាយណ៍រាជាទី ២<br>ឧទ័យរាជា<br>អង្គតន់ | ១៧៥៨-១៧៧៥ | ព្រែកមាត់កណ្តុរ<br>ព្រែកពាក់ព្រ័ត<br>កោះចិន<br>ឧដុង្គ | ចៅព្រះរាមាធិបតីទី ៣<br>អង្គទង |
| 2 | រាមរាជា<br>អង្គនន់ | ១៧៧៥-១៧៧៩ | ឧដុង្គ | បុត្រស្រីជ័យជេដ្ឋ<br>អង្គស្ងួន |

| | | | | |
|---|---|---|---|---|
| 3 | នារាយណ៍រាជាទី ៣ អង្គអេង | ១៧៧៩-១៧៩៦ | ឧដុង្គ | បុត្រព្រះឧទ័យរាជា អង្គតន់ |
| 4 | ចៅហ៊្វាប៉ុក | ១៧៩៦- ១៨០៥ | ឧដុង្គ | |
| 5 | ឧទ័យរាជា អង្គចន្ទ | ១៨០៦- ១៨៣៤ | ឧដុង្គ ភ្នំពេញ | បុត្រស្តេច ៣ |
| 6 | អង្គម៉ីក្សត្រី | ១៨៣៤-១៨៤០ | កោះស្លាកែត | បុត្រីស្តេច ៥ |
| 7 | ហរិរក្សរាមាឥស្សរា-ធិបតី អង្គដួង | ១៨៤០-១៨៥៩ | ឃ្លាំងស្បែក ឧដុង្គ | បុត្រស្តេច ៣ |
| 8 | នរោត្តម អង្គច្រឡឹង-អង្គវតី | ១៨៥៩-១៩០៤ | ឧដុង្គ ភ្នំពេញ | បុត្រស្តេច ៧ |
| 9 | ស៊ីសុវត្ថិ | ១៩០៤-១៩២៧ | ភ្នំពេញ | បុត្រស្តេច ៧ |
| 10 | ស៊ីសុវត្ថិ មុនីវង្ស | ១៩២៧-១៩៤១ | ភ្នំពេញ | បុត្រស្តេច ៩ |

## សេចក្តីបញ្ចប់

យើងសូមបញ្ចប់ការសិក្សារបស់យើងត្រឹមរជ្ជកាលព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** នោះ ។ ចំណែកឯប្រវត្តិសាស្ត្រខ្មែរសម័យចាប់ពីឆ្នាំ ១៩៤១តទៅ យើងសូមប្រគល់ភារៈនេះជូនទៅអ្នកស្រាវជ្រាវដទៃទៀតអោយជួយចងក្រងទុកសំរាប់អោយកូនចៅខ្មែរបានដឹងបានលឺផង ។

ការសិក្សារួចមកហើយបានបង្ហាញអោយឃើញថា ខ្មែរជាជាតិមួយមានចំណាស់បានកកើតឡើងបានរស់នៅ និង បានវិវត្តហូរហែមកតាំងពីប្រមាណ ២០០០ឆ្នាំមុនគ្រិស្តសករាជម្ល៉េះ នៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ ប្រជាជាតិខ្មែរក៏ដូចជាជាតិដទៃទៀតនៅក្នុងពិភពលោកយើងនេះដែរ តែងតែបានជួបប្រទះនូវការប្រែប្រួល ជួនកាលបានថ្កុំថ្កើងរុងរឿងដូចនៅសម័យនគរភ្នំ សម័យចេនឡា សម័យមហានគរ ជួនកាលទៀតក៏ធ្លាក់ដុនដាបបានដល់នូវសេចក្តីវេទនារកទីបំផុតគ្មានដូចនៅសម័យក្រោយអង្គរ ។ ប៉ុន្តែ យើងមិនត្រូវផ្តេកផ្តួលទៅលើច្បាប់ធម្មជាតិដូចបានពោលខាងលើហើយនាំគ្នាអស់សង្ឃឹមពីវាសនាប្រទេសជាតិរបស់ខ្លួនទេ ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់គ្រប់ជាន់ថ្នាក់ត្រូវតែខិតខំរៀនសូត្រប្រវត្តិសាស្ត្ររបស់ជាតិខ្លួនអោយបានដឹងច្បាស់គ្រប់គ្នាឡើង ដើម្បីអោយមានការភ្ញាក់

រលឹក អោយចាប់អារម្មណ៍លើបញ្ហាជាតិ បានសេចក្តីថាដើម្បីអោយមានមនសិការជាតិដ៏ពេញលេញ ជាពិសេសនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះដែលប្រទេសជាតិកំពុងតែត្រូវការអ្នកស្នេហាជាតិដើម្បីការពារទឹកដី និងដើម្បីធ្វើការកសាងជាតិក្នុងពេលបច្ចុប្បន្ន និងអនាគតខាងមុខនេះ ។

ការដែលយើងដឹង និងស្គាល់ច្បាស់ពីកំហុស ពីការភ័ន្តច្រឡំរបស់ដូនតាយើង និងពីឧបាយកលផ្សេងៗ របស់ជនជាតិជិតខាងក្នុងការប្រវ័ញ្ចយកទឹកដី និងក្នុងបំណងបំបាត់ពូជសាសន៍ខ្មែរ ពុំមែនគ្រាន់តែអោយដឹង អោយឈឺចាប់ទទេៗ ហើយលាន់មាត់ស្តីបន្ទោស រួចបំភ្លេចចោលទៅវិញនោះទេ តែការសំខាន់ គឺត្រូវចេះទាញយកមេរៀន ទាញយកការពិសោធន៍ពីហេតុការណ៍ទាំងឡាយដែលបានកើតឡើងរួចហើយ ហើយធ្វើយ៉ាងណាដើម្បីចៀសវាងកុំអោយធ្លាក់ទៅក្នុងគន្លងចាស់ដែលនាំអោយខូចប្រយោជន៍ជាតិទៀត ។

ម្យ៉ាងទៀត យើងក៏សូមបញ្ជាក់ទៀតដែរថា ដែលយើងបង្ហាញការពិតជាក់ស្តែងពីឧបាយកលរបស់ជនជាតិជិតខាងយើង គឺមិនមែនក្នុងគោលបំណងធ្វើអោយមានអរិភាព អោយមានគំនុំគំគួនប្រទូស្តរាយគ្នាមិនចេះចប់នោះទេ ។ ខ្មែរយើងចង់តែរស់នៅដោយសុខសាន្តជាមិត្តជាមួយប្រទេសជិតខាងអោយតែប្រទេសទាំងនោះគោរពបូរណភាពទឹកដី ឯករាជ្យ អធិបតេយ្យ ផលប្រយោជន៍របស់ខ្មែរ ។

ដូច្នេះ ឃើញថាការសិក្សាប្រវត្តិសាស្ត្រពុំមែនជាការឥតប្រយោជន៍ដូចជនចំពូកខ្លះបានយល់នោះទេ ។ ប្រវត្តិសាស្ត្រជាកញ្ចក់អោយយើងឆ្លុះមើលអោយស្គាល់អតីតកាលជាតិ កំណើតរបស់យើងអោយបានច្បាស់លាស់ ដែលជាហេតុអោយយើងបានយល់ពីព្រឹត្តិការណ៍ក្នុងបច្ចុប្បន្នកាល ព្រមទាំងប្រមាណមើលនូវទស្សនវិស័យរបស់ជាតិក្នុងអនាគតកាលថែមទៀត ។

បញ្ហាចម្បងរបស់ខ្មែរក្នុងពាក់កណ្តាលទី ២ នៃសតវត្សនេះ គឺការថែរក្សាពូជសាសន៍ខ្មែរ និងទឹកដីដែលនៅសល់មួយក្រវិចនេះអោយនៅគង់វង់យូរអង្វែងតទៅទៀត ។ ប្រសិនបើប្រជាពលរដ្ឋខ្មែរមិនបានស្គាល់ច្បាស់ប្រវត្តិសាស្ត្ររបស់ខ្លួនហើយបណ្តោយអោយប្រទេសជាតិធ្លាក់ទៅក្រោមនឹមត្រួតត្រារបស់បរទេសហើយ កូនចៅខ្មែរនឹងត្រូវបាត់បង់អស់សិទ្ធិសេរីភាពក្នុងការរស់នៅ ហើយមិនយូរប៉ុន្មាននឹងត្រូវរលាយជាតិបាត់ឈ្មោះពីផែនទីសាកលលោកជាមិនខាន !

ភ្នំពេញ ថ្ងៃ១១ ខែកញ្ញា ១៩៧៤

អ្នកនិពន្ធ

# បញ្ជីឯកសារពិគ្រោះ


1. Henri Marchal, Angkor, Paris, 1955

2. Revue France-Asie, nº spécial pour la civilisation khmère, Saigon, 1955

3. ឯកសារមហាបុរសខ្មែរលេខ៤ បោះពុម្ពផ្សាយដោយលោកអេងសុតនៅភ្នំពេញគ. ស. ១៩៦៩

4. លោកកងគីរី-លោកសែមសួរ : ប្រជុំអនុពាក្យទំនើប ទំព័រ ៨៤ -កំពង់ចាម-១៩៦៣ ។

5. សម្ដេចព្រះមហាសុមេធាធិបតី ជួនណាត-ប្រវត្តិនៃវត្តឧណ្ណាលោម-ភ្នំពេញ គ. ស. ១៩៥៣ ។

6. លោកស៊ឹមវ៉ា និងលោកលីអេង - ប្រវត្តិនៃប្រទេសកម្ពុជា (សាកល្បង) បោះពុម្ពហើយ តែមិនបានផ្សាយនៅភ្នំពេញ គ. ស. ១៩៦៩ ។

7. Etienne Aymonier, Le Cambodge , tome III, Paris, 1904.

8. បែបរៀនសង្គមសិក្សា វិជ្ជាប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សាឆ្នាំទី១ របស់ក្រុមវិជ្ជាការក្រសួងសិក្សាធិការ (ភាសាថៃ) បឹងកក -ព. ស. ២៥១២ គ. ស. ១៩៦៨ ។

9. Dauphin Meunier, Histoire du Cambodge, PUF , Que sais -je ? Paris 1961.

10. -12- Henri Russier, Histoire sommaire du royaume du Cambodge des origines à nos jours (brochure ronéotypée), 1929 ?

11. Adhémard Leclère, le Sdach Kân, Imprimerie coloniale, Saigon, 1911.

13. Lê Thanh Khôi, Histoire de l'Asie du Sud - est, PUF , Que sais-je ? Paris, 1959.

14. B.P. Groslier, Angkor et le Cambodge au 16º siècle d'après les sources portugaises et espagnoles, Paris, 1958.

15. France- Asie, nº spécial 118-119, Présence du Royaume lao, Saigon. 1956.

16. ពង្សាវតារប្រទេសលាវ គឺក្រុងហ្លួងព្រះបាង ក្រុងវៀងចន្ទ ក្រុងជួន និងក្រុងចំប៉ាស័ក (ជាភាសាលាវ) - វៀងចន្ទ គ. ស. ១៩៦៧ ។ Annales de Laos-Luang Prabang- Vientiane - Tranninh et Bassac, publiées la 22e année du règne de S.M. Sisavang Vong Roi du Luang Prabang, 1926.

17. ឯកសារមហាបុរសខ្មែរ លេខ ២៧-២៨ របស់លោកអេងសុត បោះពុម្ពផ្សាយនៅក្រុងភ្នំពេញ នៅគ. ស. ១៩៦៩ ។

18. ប្រវត្តិវិទ្យា ភាគ ១ ថ្នាក់ទី ១ - ខេមរយានកម្ម - ភ្នំពេញ - ១៩៧២ ។

19. Lawrence Palmer Priggs, Les missionnaires portugais et espagnols au Cambodge (1555-1603), texte traduit de l'anglais par Monique Dupont et publié dans Fullectin de la Société des Etudes Indochinoises (Nouvelle série - Tome xxv, n° 1-1er trimestre 1950), Saigon, 1950.

20. H. Sutton, Singapore in history, federal publications, Singapore, 1967.

21. ព្រះរាជពិធីទ្វាទសមាស ភាគ ១ បោះពុម្ពលើកទី ២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០០ - គ.ស. ១៩៥៦ ។

22. J. Imbert, Histoire des Institutions Khmères, volume II, Annales de la Faculté de Droit de Phnom Penh, 1961.

23. លោកអនុសេនីយឯក សឺននី - ប្រវត្តិយោធាខ្មែរ អត្ថបទផ្សាយតាមទូរទស្សន៍សាធារណរដ្ឋខ្មែរ ខែ មេសា ១៩៧៤ ។

24. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦ - ភ្នំពេញ ១៩៦៩ ។

25. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត-លេខ ១២-១៦-១៨ ភ្នំពេញ ១៩៦៩ ។

26. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

27. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ១៥ - ភ្នំពេញ គ.ស. ១៩៦៩ ។

28. សិលាចារឹកនគរវត្ត និងបទានុក្រម - ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៥៨ ។

29. គោលប្រវត្តិសាស្រ្តនៃអក្សរសាស្រ្តខ្មែរ ដោយប្រជុំសាស្រ្តាចារ្យ-ការផ្សាយរបស់បណ្ណាគារភ្នំពេញ - ភ្នំពេញ គ.ស. ១៩៥៦ ។

30. លោក ឃួន សុខម្ហ - គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ - សន្និសីទធ្វើនៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី ១ មិថុនា ១៩៧៤ នៅភ្នំពេញ ។

31. L'organisation buddhique au Cambodge, n°4 , Série Cuture et Civilisation Khmères, Phnom Penh, 1963.

32. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២២ - ភ្នំពេញ គ.ស. ១៩៦៩ ។

33. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២៣ - ភ្នំពេញ គ.ស. ១៩៦៩ ។

34. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

35. Madeleine Giteau, Depuis un siècle, un effort soutenu pour dégager et restaures Angkor, dans SOS Angkor, Courrier de L'Unesco, Décembre 1961.

36. ប្រជុំពង្សាវតារ ច្បាប់បណ្ណាល័យជាតិ- ក្បាលទី១ - រោងពុម្ពការហ្នា បោះពុម្ពលើកដំបូង - ក្បាលទី ១ ឧសភា ព.ស.២៥០៦ ( ជាភាសាថៃ) ។

37. Phan Khoang, Viêt Su : Xu Dang Trong 1558-1777, Saigon, 1969.

38. Lê Huong, Su Cac Miên, Saigon, 1970.

39. Charles Meyer, Phnom Penh, à la recherche du passé - les premiers occidenteaux à Phnom Penh, article publié dans Nokor Khmer, n°2, Phnom Penh, 1970.

40. Tran Trong Kim, Vietnam Su Luoc, Sagon, 1964.

41. G. Nandin, Histoire de la Cochinchine.

42. Jean Moura, Le Royaume du Cambodge, Paris, 1883.

43. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦៤ - ភ្នំពេញ គ.ស.១៩៦៩ ។

44. Adhémard Leclère, l'Histoire du Cambodge, Geuthner, Paris, 1914.

45. Lê Huong, Nguoi Viet gôc Miên, Sagon, 1969.

46. P. Schweisguth, un siècle d'histoire dans la péninsule indochinoise (1750-1850), Imprimerie Taupin et , Hanôi, 1944.

47. លោក កែវសុវត្ថិ - ចៅហ្វាយគុយ - ភ្នំពេញ - ១៩៧១ ។

48. Gérard Groussin,,Le protectorat Français sur le Cambodge de 1863 à 1884 (ronéotypé), Centre de documentation et de recherche de la Faculté des Lettres et des Sciences humaines de Phnom Penh, 1973.

49. Luang vichitr Vadakarn, Thailand's case, Bangkok, 1941.

50. Charles Meyer, Insurrections nationales du siècle dernier, dans Etudes cambodgiennes n° 9 , Phnom Penh, 1967.

51. M. Giteau, Histoire du Cambodge, Didier, Paris, 1957.

52. លោក ឱកគាម - អាចារ្យស្វា - ភ្នំពេញ គ.ស. ១៩៧៣ ។

53. La monarchie khmère, dans le Sangkum nº 5, décembre 1965, Phnom Penh.

54. L'histoire de Kralahom Kong par ImChhum (traduction libre Suon On et Charles Meyer), dans Etudes cambodgiennes nº 18, Phnom Penh, 1969.

55. Gaston Barrault, Cambodgiens de Cochinchine, Editions de la Revue Extrême - Orient, Saigon, 1927.

56. La frontière Khméro - vietnamienne, dans Etudes Cambodgiennes nº 7 Phnom Penh, 1966.

57. Sarin Chhak, Quelques faits historiques sur le tracé des frontières entre le Cambodge, le Laos et le Vietnam ចុះផ្សាយក្នុងទស្សនាវដ្ដីសាស្ត្រចារ្យ លេខ ១៤- ឆ្នាំទី ៥- ១៩៦៤ ។

58. La monarchie khmère, dans le Sangkum nº 6, Phnom Penh, 1966.

59. Ho Tong Peng, L'économie de l'hévéaculture en 1965, dans Etudes cambodgiennes nº 1, Phnom Penh, 1965.

60. លោក ឱកគាម និងលោក ឡឿកអំ - ភូមិគីរិថ្លាន - ភ្នំពេញ -គ.ស. ១៩៧១ ។

61. L'oeuvre de Sa Majesté Monivong, dans le Sangkum nº 8 Phnon Penh, 1966.